# កម្ពុជាក្រោម

ព្រឹត្តិបត្របោះពុម្ពផ្សាយជារៀងរាល់ខែ ដោយសហព័ន្ធខ្មែរកម្ពុជាក្រោម

លេខ ១៥ ឆ្នាំទី ០២ - ខែមីនា គ.ស. ២០០៥ - ព.ស. ២៥៤៨ - N⁰ 15, March, 2005


# ស្ត្រីខ្មែរកម្ពុជាក្រោមចូលរួមទិវាសិទ្ធិនារីអន្តរជាតិ ០៨ មីនា

## លិខិតតំណាងស្ត្រីខ្មែរក្រោម ផ្ញើប្រគេនព្រះសង្ឃ ជូនស្ត្រី និងជនរួមជាតិខ្មែរក្រោមទូទាំងពិភពលោក នាទិវាសិទ្ធិនារីអន្តរជាតិលើកទី ៩៥ (០៨ មីនា ២០០៥)

*-សូមក្រាបថ្វាយបង្គំព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីគោរព !*

*-សូមគោរពបងប្អូននារីខ្មែរកម្ពុជាក្រោម ទូទាំងពិភពលោក ជាពិសេសបងប្អូននារីខ្មែរកម្ពុជាក្រោម ដែលកំពុងរស់នៅក្នុងមាតុភូមិកម្ពុជា-ក្រោម និង បងប្អូនរួមជាតិខ្មែរកម្ពុជាក្រោមនៅលើពិភពលោក ជាទីគោរពរាប់អាន និងជាទីនឹករឭក !*

ថ្ងៃទី ០៨ មីនា នេះ ជាទិវាប្រកបដោយបរិយាកាសសប្បាយរីករាយសម្រាប់ស្ត្រីទូទាំងពិភពលោក ។ ដោយឡែកស្ត្រីខ្មែរ នៅក្នុងប្រទេស ក៏ដូចជានៅក្រៅប្រទេស ក៏បានរៀបចំពិធីអបអរសាទរ និងដើម្បីរំឭកខួបឆ្នាំទី ៩៥ នៃទិវានារីអន្តរជាតិ ដែលត្រូវបានអង្គការសហប្រជាជាតិបានទទួលស្គាល់ និង ផ្តោតការយកចិត្តទុកដាក់ជាសំខាន់ទៅលើសិទ្ធិសេរីភាពរបស់នារីទូទាំងពិភពលោក ។

តាងនាមនារីខ្មែរក្រោម និងក្នុងនាមខ្ញុំព្រះករុណានាងខ្ញុំផ្ទាល់ សូមចូលរួមអបអរសាទរយ៉ាងកក់ក្តៅជាទីបំផុតនូវទិវាដ៏ឧត្តុង្គ-ឧត្តមនេះ ។

ថ្វីបើនារីនៅលើសកលលោកធ្វើចលនាតស៊ូទាមទារនូវសិទ្ធិនារី ជិត ១០០ ឆ្នាំ ហើយរដ្ឋាភិបាលជាច្រើននៅលើពិភពលោក ក៏បានទទួលស្គាល់ និងយល់ព្រម ប្រគល់សិទ្ធិ ដល់ស្ត្រីនៃប្រទេសរបស់គេក្តី ក៏បងប្អូននារីខ្មែរក្រោមយើង នៅតែមានវាសនាអាក្រក់ ដោយពុំបានទទួល នូវសិទ្ធិជាមូលដ្ឋានណាមួយពីសំណាក់រដ្ឋាភិបាលអា-ណានិគមយួន គ្រប់ជំនាន់ និងគ្រប់និន្នាការឡើយ ។ លើសពីនោះទៀត រដ្ឋាភិបាលអា-ណានិគមយួនគ្រប់ជំនាន់ ជាពិសេស រដ្ឋាភិបាលយួនកុម្មុយនិស្តបច្ចុប្បន្ន នៅតែបន្តការរំលោភបំពាន មកលើនារីខ្មែរក្រោម ពុំឈប់ឈរ និងធ្វើទុក្ខបុកម្នេញនារីខ្មែរក្រោម ឲ្យរងទុក្ខវេទនាជាអាលជ្ជី ដូចជា ៖ ការចាប់បង្ខំបុរសជាប្តី ឲ្យទៅបំពេញកាតព្វកិច្ចយោធា ការចោទប្រកាន់បុរសជាស្វាមីដោយលេសផ្សេង ៗ រួចចាប់ដាក់ពន្ធនាគារ ឬ គំរាមកំហែងបង្ខំឲ្យចាកចេញពីស្រុកកំណើតរបស់ខ្លួន បានតម្រូវឲ្យនារីខ្មែរក្រោមទទួលរ៉ាប់រងតែម្នាក់ឯងក្នុងការចិញ្ចឹមកូន និងធ្វើកិច្ចការផ្សេង ៗ នៅក្នុងគ្រួសារដែលជាបន្ទុកមួយដ៏ធ្ងន់សម្រាប់នារីខ្មែរក្រោម ។ ទុក្ខវេទនារបស់ស្ត្រីខ្មែរក្រោមទាំងនោះត្រូវបាន អាជ្ញាធរយួនធ្មេចភ្នែក ធ្វើជាមើលពុំឃើញ និងពុំបានយកចិត្តទុកដាក់ ជួយឧបត្ថម្ភឡើយ ។ ផ្ទុយទៅវិញ គេបែរជាបំភិតបំភ័យ និងចោទប្រកាន់ទៅលើគ្រួសារស្ត្រីទាំងនោះ ថាជាគ្រួសារក្បត់ពុំស្មោះត្រង់នឹងរដ្ឋអំណាចថែមទៀត ។

ជីវិតរស់នៅក្រោមការគាបសង្កត់របស់រដ្ឋាភិបាលយួនដែលមានមហិច្ឆិតាដ៏ធំធេង និងគំនិតជាអមតៈក្នុងការរំលាយពូជសាសន៍ខ្មែរកម្ពុជាក្រោមនោះ នារីខ្មែរក្រោមភាគច្រើនត្រូវស្ថិតក្នុងអនក្ខរ-ភាព ។ ឆ្លៀតឱកាសនេះ រដ្ឋាភិបាលយួនពុំដែលធ្វើការផ្សព្វផ្សាយអប់រំ ឬ ណែនាំនារីខ្មែរក្រោមឲ្យបានយល់ បានឮ ឬ បានដឹងអំពីសិទ្ធិជាមូលដ្ឋានរបស់ខ្លួន ហើយមិនដឹងថា នារីមានសិទ្ធិយ៉ាងដូចម្តេចខ្លះក្នុងជីវិតរស់នៅរបស់ខ្លួនឡើយ ។



*ស្ត្រីខ្មែរក្រោម នៅក្នុងអង្គការសហប្រជាជាតិ នាថ្ងៃទី ០៨ មីនា ២០០៥*

## មាតិការឿង


-ស្ត្រីខ្មែរកម្ពុជាក្រោមចូលរួម ........................ ១
-ប្រយ័ត្នបាត់បង់ស្មារតីជាតិ ........................ ៣
-ព្រះមហាវីរក្សត្រ ........................ ៤
-លិខិតអំពាវនាវ ........................ ៥
-ពុទ្ធបរិស័ទនៅគ្រប់ទិសទី ........................ ៦
-ឆ្នាំព្រំដែនយួនធ្វើទុក្ខព្រះសង្ឃ ........................ ៧
-រឿងកំពប់តែអុង ........................ ៨
-ប្រវត្តិវត្តចូឡាមណីចេតិយ ........................ ១១
-វេទិកាគំនិតជាតិ ........................ ១២
-រឿងមហាសុរសេន........................ ១៤
-បទចម្រៀង កម្លាំងសាមគ្គី ........................ ១៦



**ទីស្នាក់ការ ៖** P.O. Box 0193, Pennsauken, NJ 08110-0193, USA, Tel: (856) 583-1503, email: kkfnewsletter@khmerkrom.net, http://www.khmerkrom.net

ចាប់ពីថ្ងៃទី ០៤ ដល់ថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ១៩៩៥ អង្គការសហប្រជាជាតិ បានរៀបចំសន្និសីទនារីពិភពលោកលើកទី ០៤ នៅទីក្រុងប៉េកាំង នៃសាធារណរដ្ឋប្រជាមានិតចិន ដោយបានលើកនូវប្រធានបទ "សមភាព វឌ្ឍនភាព និងសន្តិភាព" ដើម្បីពិភាក្សា និងដាក់ចេញនូវកង្វល់ ១២ យ៉ាងរបស់នារីនៅលើពិភពលោក មានភាពក្រីក្ររបស់នារី ការអប់រំ អំពើហិង្សា ផលវិបាកនៃជម្លោះប្រដាប់អាវុធ នារីនៅក្នុងរចនាសម្ព័ន្ធនយោបាយ និងសេដ្ឋកិច្ច តួនាទីនារីក្នុងយន្ត-ការលើកកម្ពស់ការរីកចម្រើនរបស់នារី សិទ្ធិនារីលើប្រព័ន្ធផ្សព្វផ្សាយ និងបរិស្ថាន និងកុមារី ។ ផែនការសកម្មភាពក្រុងប៉េកាំងអំពីបញ្ហាស្ត្រីពីឆ្នាំ ១៩៩៥ ដល់ ២០០៥ នេះ គឺជាគោលការណ៍មួយដែលតម្រូវឲ្យរដ្ឋាភិបាលគ្រប់ប្រទេសនៅលើសកលលោក ត្រូវយកអស់ពីសមត្ថ-ភាពធ្វើយ៉ាងណាឲ្យ នារីទទួលបាននូវសិទ្ធិទាំងអម្បាលមាណខាងលើនេះ ជាអតិបរមា ។

ក្នុងខែមីនា ឆ្នាំ ២០០៥ នេះដែរ អង្គការសហប្រជាជាតិតម្រូវឲ្យប្រទេសដែលជាសមាជិក ធ្វើរបាយការណ៍អំពីការអនុវត្តផែនការសកម្មភាពក្រុងប៉េកាំង ស្តីអំពីស្ត្រី ពីឆ្នាំ ១៩៩៥ ដល់ ២០០៥ នេះផងដែរ ។

បើពិនិត្យមើលការអនុវត្តនូវផែនការក្តីកង្វល់ ១២ យ៉ាងរបស់ស្ត្រីនៃសន្និសីទនារីពិភពលោកលើកទី ០៤ នាទីក្រុងប៉េកាំង ឆ្នាំ១៩៩៥ នោះ ទោះបីជាសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលជាសមា-ជិក នៃអង្គការសហប្រជាជាតិមួយផងដែរនោះ បានដឹងបានឮអំពីបញ្ហានេះហើយក៏ដោយ ក៏ក្នុងរយៈពេល ១០ ឆ្នាំ នេះ រដ្ឋាភិបាលយួនកុម្មុយនិស្ត មិនបានយកចិត្តទុកដាក់អនុវត្តនូវកង្វល់ទាំង ១២ យ៉ាងរបស់ស្ត្រីខ្មែរក្រោមឡើយ ។ ទង្វើបែបនេះ បានធ្វើឲ្យស្ត្រីខ្មែរក្រោមបាត់បង់នូវសិទ្ធិសេរីភាព និងទទួលរងគ្រោះដោយប្រការផ្សេង ៗ យ៉ាងធ្ងន់ធ្ងរ ។ ជាក់ស្តែង ៖

-នារីខ្មែរក្រោមភាគច្រើន រស់នៅក្នុងភាពក្រីក្រ ធ្វើការមួយថ្ងៃ ៗ គ្មានពេលសម្រាក បរិភោគអាហារមិនគ្រប់គ្រាន់ និង ពុំមានជីវជាតិ ។

-ពេលឈឺថ្កាត់ និងពេលសម្រាលកូន នារីខ្មែរក្រោម ត្រូវប្រឈមមុខនឹងការខ្វះខាតថ្នាំសង្កូវសម្រាប់ព្យាបាល និងបំប៉នសុខ-ភាព ដោយសារជីវភាពក្រីក្រ ។

-ស្ទើរតែគ្មាននារីខ្មែរក្រោមណាម្នាក់បានចូលរួមក្នុងសកម្ម-ភាពនយោបាយ ដើម្បីដឹកនាំសង្គមខ្មែរកម្ពុជាក្រោម ឈានទៅរកការរំដោះខ្លួន ឲ្យរួចចាកផុតពីការជិះជាន់ឡើយ ។ នារីខ្មែរកម្ពុជាក្រោមចំនួនតិចតួចបំផុត ដែលត្រូវបានរដ្ឋាភិបាលយួនកុម្មុយនិស្ត បញ្ចូលឲ្យធ្វើសកម្មភាពនយោបាយ ក្នុងផ្នែកអង្គការមហាជនរបស់រចនាសម្ព័ន្ធនៃបក្សកុម្មុយនិស្តយួន ។ គោលបំណង គឺដើម្បីបម្រើមនោគមវិជ្ជានិងផលប្រយោជន៍របស់គេតែប៉ុណ្ណោះ ហើយពុំមានសិទ្ធិក្នុងការធ្វើសកម្មភាពបម្រើផលប្រយោជន៍ខ្មែរកម្ពុជាក្រោម ដែលជាម្ចាស់ទឹកដីនិងជាជនជាតិដើមនៅក្នុងសហគមន៍វៀតណាមឡើយ ។

-នារីខ្មែរក្រោមភាគច្រើន ទទួលរងនូវអំពើហិង្សាពីសំណាក់ស្វាមី ។

-នារីខ្មែរក្រោមស្ថិតក្នុងភាពជាស្ត្រីមេម៉ាយ ឬ ស្រីប្តីព្រាត់ដែលត្រូវរ៉ាប់រងបន្ទុកគ្រួសារយ៉ាងធ្ងន់ធ្ងរ អាស្រ័យដោយស្វាមីត្រូវចូលបម្រើក្នុងជួរកងទ័ព ធ្វើសង្គ្រាមតាមមហិច្ឆិតានៃរដ្ឋអំណាចយួន ឬ ត្រូវរដ្ឋអំណាចយួនចាប់ដាក់គុកច្រវាក់ និងបំភិតបំភ័យឲ្យរត់ចោលស្រុកជាដើម ។

ចំពោះការបាត់បង់សិទ្ធិសេរីភាព និងទុក្ខកង្វល់របស់ស្ត្រីខ្មែរក្រោមខាងលើនេះ រដ្ឋអំណាចកុម្មុយនិស្តយួន ពុំដែលយកចិត្តទុកដាក់អប់រំ ណែនាំ និងគោរពសិទ្ធិនារីខ្មែរក្រោមឡើយ ។ ដូចជាមិនបានចែកចាយឯកសារស្តីពីសិទ្ធិនារីដល់នារីខ្មែរក្រោម ពុំបានសាងសង់សាលារៀន ឬ បញ្ចូលកម្មវិធីសិក្សាអក្សរសាស្ត្រនៅក្នុងសាលាចំណេះទូទៅសម្រាប់នារីខ្មែរក្រោមរៀនសូត្រឡើយ នៅពេលដែលនារីខ្មែរក្រោម ពុំមានលទ្ធភាពចូលទៅរៀនអក្សរសាស្ត្រខ្មែរនៅក្នុងវត្តអារាមនោះ ។ មិនត្រឹមតែប៉ុណ្ណោះ រដ្ឋអំណាចយួនកុម្មុយនិស្ត ពុំបានយកចិត្តទុកដាក់ក្នុងការសាងសង់ទារកដ្ឋាន ឬ អាគារសម្ភពនៅក្នុងតំបន់ដែលមានខ្មែរកម្ពុជាក្រោមរស់នៅឡើយ ។

នៅក្នុងឱកាសរំឭកខួបឆ្នាំទី ៩៥ នៃទិវាសិទ្ធិនារីអន្តរជាតិ ០៨ មីនា ឆ្នាំ ២០០៥ នេះ តាងនាមនារីខ្មែរក្រោម និងក្នុងនាមនាងខ្ញុំផ្ទាល់ នាងខ្ញុំសូមអំពាវនាវដល់នារីខ្មែរក្រោមទាំងនៅក្នុងមាតុភូមិកម្ពុជាក្រោម ទាំងនៅក្រៅប្រទេស ក៏ដូចជាប្រជាពលរដ្ឋខ្មែរក្រោមគ្រប់រូប សូមក្រោកឈរឡើងទាមទារនូវសិទ្ធិសេរីភាព ដែលត្រូវទទួលរងនូវការរំលោភបំពានពីអាជ្ញាធរយួន ពិសេសជម្រុញឲ្យរដ្ឋាភិបាលយួនកុម្មុយនិស្ត អនុវត្តឲ្យបានតាមផែនការសកម្មភាពក្រុងប៉េកាំង ស្តីពីបញ្ហាស្ត្រី ពីឆ្នាំ ១៩៩៥ ដល់ ២០០៥ តាមមាគ៌ាដឹកនាំរបស់សហ-ព័ន្ធខ្មែរកម្ពុជាក្រោម ដើម្បីនារីខ្មែរក្រោមមានសិទ្ធិគ្រប់គ្រាន់ ក្នុងការអនុវត្តសិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង តាមគោលការណ៍របស់សហព័ន្ធ ។

នាងខ្ញុំសូមប្រគេនពរ និង ជូនពរដល់ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ជនរួមជាតិ ជាពិសេសនារីខ្មែរក្រោម ព្រមទាំងស្ត្រីនៅលើពិភពលោក សូមឲ្យបានទទួលជោគជ័យគ្រប់ភារកិច្ច ក្នុងការលើកតម្កើងសិទ្ធិនារីកុំបីខកខានឡើយ ៕

*សូមអរព្រះគុណ និងអរគុណ !*
*សហរដ្ឋអាមេរិក, ថ្ងៃទី ០៨ ខែមីនា ឆ្នាំ ២០០៥*
*នាងខ្ញុំ សឺន ធីនិត*

និពន្ធនាយក ៖ **ថាច់ ប៊ុកថាច់** ផ្សព្វផ្សាយ ៖ **សឺន រតនៈ, សឺន ច័ន្ទ**
ឯកសារ PDF មាននៅក្នុងគេហទំព័រ www.khmerkrom.net

# ប្រយ័ត្នបាត់បង់ស្មារតីជាតិ

"នៅពេលណារដ្ឋាភិបាលក្រុងហាណូយផ្តល់អំណោយ ឬសម្ភារៈដល់បុគ្គលណាមួយ គ្រួសារណាមួយ ក្រុម ភូមិ ស្រុកណាមួយ នូវសេចក្តីត្រូវការចាំបាច់ ដែលទាក់ទងនឹងជីវិតប្រចាំថ្ងៃនោះ វានឹងបណ្តាលឲ្យបងប្អូនជនរួមជាតិយើងបាត់បង់នូវឆន្ទៈស្នេហាជាតិ លះបង់នូវការតស៊ូ និងលែងទទួលស្គាល់នូវតម្លៃសង្គមខ្លួនឯង" ។

### ស្ថានការណ៍បច្ចុប្បន្ន

ក្រុងហាណូយបានទទួលស្គាល់ថា ផែនការរំលាយពូជសាសន៍ ដែលខ្លួនអនុវត្តបន្តពីដូនតាខ្លួននោះ និងនាំមកនូវមហន្តរាយដល់ខ្លួនមិនខានក្នុងអនាគតដ៏ខ្លីខាងមុខនេះ ។ ដោយមើលឃើញយ៉ាងច្បាស់ក្រឡែតនូវស្មារតីតស៊ូរបស់ជនជាតិដើម មានកម្រិតខ្លាំងក្លានាដើមសតវត្សទី ២១ នេះនៅជុំវិញពិភពលោក ។ ដើម្បីបន្ថយល្បឿនការតស៊ូនៃជនជាតិដើមនោះ ក្រុងហាណូយបានបង្ខំខ្លួនចុះហត្ថលេខាលើសន្ធិសញ្ញាជាមួយអង្គការសហប្រជាជាតិ មានជាអាទិ៍ ៖ សិទ្ធិមនុស្ស សិទ្ធិស្រ្តី សិទ្ធិបង្កើតសមាគម ជំនឿ ។ល។ និង ។ល។ ដោយនឹកស្មានថា ខ្មែរក្រោមគ្មានក្រឡាលោត ឬ បាក់ស្បាតអស់ហើយ ។ ដូច្នេះអ្វី ៗ ដែលគេបានចុះហត្ថលេខា ឬ ព្រមព្រៀងជាមួយអង្គការសហប្រជាជាតិ គ្រាន់តែដើម្បីឲ្យប្រទេសនានាមកធ្វើវិនិយោគទុនជាមួយប្រទេសខ្លួនតែប៉ុណ្ណោះ ។ ការគំរាមកំហែងរបស់គេមានជានិច្ចដូចជាការឆែកឆេរតឹងរឹងលើខ្មែរក្រោម ដែលទៅលេងស្រុកកំណើត ការតឹងរឹងមិនឲ្យយកសម្ភារៈពីកម្ពុជា ។ ដោយឡែកនៅក្នុងស្រុកឯណោះវិញ គេធ្វើការជំរិតរឹបអូសយកដីស្រែពីខ្មែរក្រោមតាមជនបទ ក៏ដូចជានៅទីណា ដែលគេលក់ទៅបានកម្រៃច្រើន ។ បើត្រង់ណាមិនមានលក្ខណៈខាងលើនេះទេ គេកសាងថ្នល់ ឬ ជីកព្រែកលើដីនោះតាមទំនើងចិត្ត ។ មិនត្រឹមតែប៉ុណ្ណោះវាបានបណ្តោយឲ្យប្រជាជនយួនមកសង់ផ្ទះសំបែងលើដីវត្តអារាមទៀតផង ។

### គំនិតទិញស្មារតី

តែគួរឲ្យអស់សំណើច នៅតាមភូមិ ឃុំ ស្រុក ខេត្តមួយចំនួនឯណោះវិញ ក្រុងហាណូយធ្វើជាបង្ខំចិត្តសង់ផ្ទះ ឲ្យគោក្របីដល់ខ្មែរក្រោមក្រីក្រ ។ ថ្មី ៗ នេះ គេបានប្រកាសផែនការអភិវឌ្ឍន៍យ៉ាងគគ្រឹកគគ្រេងសម្បើមខ្លាំងណាស់ ក្នុងការកសាងជីវភាពខ្មែរក្រោម ។ តែការពិតនោះ វាជាការថ្នេបន្លំអន្តរជាតិ ជាពិសេសសម្រួលដើម្បីមកឆ្លើយ និងបកស្រាយនៅអង្គការសហប្រជាជាតិនៅខែឧសភា ដែលនៅពេលនោះមានសហព័ន្ធខ្មែរកម្ពុជាក្រោម នឹងទៅជម្រាបជូនអង្គការសហប្រជាជាតិពីគម្រោងដែលក្រុងហាណូយធ្វើ និងកំពុងតែអនុវត្តនៅកម្ពុជាក្រោម ។

សូមជនរួមជាតិមេត្តាពិនិត្យមើលឲ្យបានច្បាស់ដោយហេតុថា ក្រុងហាណូយរៀបផែនការតែពីរប៉ុណ្ណោះ គឺ ៖

១-បំបាត់ភាពក្រីក្រ ដែលបានសម្រេចតាំងពីឆ្នាំ ២០០០ ម្ល៉េះ ។

២-បង្កើនកម្រិតសិក្សាថ្នាក់បឋមសិក្សាឲ្យប្រសើរឡើង

ទាំងអស់នេះជាគំនាបអន្តរជាតិ ដែលបង្ខំឲ្យមេដឹកនាំក្រុងហាណូយគ្មានច្រកចេញ ។ រួមសេចក្តីមកដូចជម្រាបខាងលើ គឺមិនមែនផែនការពិតប្រាកដដូចវាអួតអាងនោះទេ មិនមែនវាធ្វើជាចិត្តល្អសង់ផ្ទះសំបែងឲ្យខ្មែរ លើកបន្តុបខ្មែរក្រោមឲ្យធ្វើជាបក្ខជន ។ល។ បើវាចិត្តបាន ចិត្តល្អនោះ ហេតុអ្វីបានជាវាជំរឹតយកដីធ្លីកសិករខ្មែរ ឲ្យជនជាតិយួនសង់ផ្ទះលើដីវត្ត មិនឲ្យនាំចូលនូវព័ត៌មានភាសាខ្មែរ និងសម្ភារៈពីប្រទេសកម្ពុជា ។

តាមទីរួមខេត្តខ្លះ មានខេត្តព្រះត្រពាំង ខេត្តឃ្លាំង ព្រែកឫស្សី ជាដើមវាប្រឹងសាងសង់ឲ្យមានសារៈមន្ទីរជនជាតិខ្មែរ ។ តែផ្ទុយទៅវិញ ពេលធ្វើបុណ្យទាន ឬ ពិធីណាមួយត្រូវតែសុំវា ប្រាប់វា មិនតែប៉ុណ្ណោះសោត វាបានបញ្ចូលព្រះពុទ្ធសាសនាខ្មែរឲ្យនៅក្រោមការត្រួតត្រារបស់វា ។

### កុំចាញ់បញ្ឆោត

ដូច្នេះអ្វី ៗ ដែលក្រុងហាណូយធ្វើ និងកំពុងធ្វើនោះ គឺដើម្បីអូសទាញស្មារតីខ្មែរក្រោមម្យ៉ាង ហើយម្យ៉ាងទៀតយកស្បែកខ្លាមកពាក់កំឡាច ។ សូមជនរួមជាតិពង្រឹងស្មារតីឡើង អ្វី ៗ ដែលវាធ្វើនោះគ្មានប្រយោជន៍ដល់ខ្មែរយើងទេ ។

យើងមិនត្រូវបណ្តោយខ្លួន ឲ្យវាកែច្នៃអូសទាញបំពុលតទៅទៀតនោះទេ គ្មានអ្វីដែលខ្មែរក្រោមត្រូវខ្លាចនូវអំពើទុច្ចរិតទាំងនោះទេ ។ ក្រុងហាណូយឥឡូវនេះ ចាប់ផ្តើមភ័យខ្លាចនូវទង្វើរបស់ខ្លួនព្រោះគេដឹងឮអស់ហើយ ដូចពាក្យលោកថា "កម្មដែលវាធ្វើវាត្រូវតែទទួល" ៕

**ថាច់ ង៉ុក ថាច់**

# ព្រះមហាវីរក្សត្រ វាយប្រហារបារាំងរឿងទឹកដីកម្ពុជាក្រោម



ព្រះមហាវីរក្សត្រ នរោត្តម សីហនុ

ភ្នំពេញ ៖ ជាមួយនឹងការបង្កើនការវាយប្រហារទៅលើការបាត់បង់ទឹកដីនៃប្រទេសកម្ពុជា ដែលធ្លាប់រុងរឿងនោះ ព្រះមហាវីរក្សត្រ នរោត្តម សីហនុ បានបន្ទោសប្រទេសបារាំងចំពោះការប្រគល់ ទឹកដីកម្ពុជាក្រោមទៅឲ្យប្រទេសវៀតណាម ដោយចាត់ទុកថានោះគឺជា "អំពើអយុត្តិធម៌ដ៏ធ្ងន់ធ្ងររបស់សាធារណរដ្ឋបារាំង" ។

នៅក្នុងអត្ថបទព្រឹត្តិបត្រព័ត៌មាន ព្រះបរមរាជវាំង កាលពីថ្ងៃ ទី ១៧ ខែ មីនា សម្តេចឪដែលគ្រោងយាងត្រឡប់មកកាន់ប្រទេសកម្ពុជានៅខែមេសា បានមានព្រះរាជបន្ទូលពន្យល់អំពីប្រវត្តិនៃជម្លោះទឹកដីកម្ពុជាក្រោម ចាប់តាំងពីឆ្នាំ ១៨៦០ នៅពេលដែលកងទ័ពអាណានិគមបារាំងធ្វើសង្គ្រាមដណ្តើមកាន់កាប់ទឹកដីកម្ពុជាក្រោម រហូតមកដល់ពេលនៃការសម្រេចប្រគល់ទឹកដីនេះ ទៅឲ្យប្រទេសវៀតណាម ។

សម្តេចឪបានមានព្រះរាជបន្ទូលថា នៅរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ខ្មែរកម្ពុជាក្រោមបាននិយាយនិងសរសេរយ៉ាងច្រើនពីការដែលប្រទេសបារាំងផ្ទេរយ៉ាងអយុត្តិធម៌ និងខុសច្បាប់ជាខ្លាំងនូវទឹកដីកម្ពុជាក្រោមនៅឆ្នាំ ១៩៤៩ ឲ្យទៅប្រទេសវៀតណាម ។ សម្តេចឪបានមានព្រះរាជបន្ទូលថា ផ្តើមចេញពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រមិនអាចប្រកែកបានដែរថា នៅពេលដែលពួកបារាំងបានធ្វើដំណើរមកកម្ពុជាក្រោម ទឹកដីកម្ពុជាក្រោមនេះ ត្រូវបានដណ្តើមកាន់កាប់តែមួយផ្នែកប៉ុណ្ណោះ ដោយកងទ័ពចក្រភពអាណ្ណាម (ឈ្មោះពីដើមរបស់វៀតណាម) ដូច្នេះប្រទេសប្រជាជាតិ និងប្រជាជនកម្ពុជាយើងមានសិទ្ធិ ព្រមទាំងកាតព្វកិច្ចនឹងធ្វើការរិះគន់ភាពអយុត្តិធម៌ដ៏ធ្ងន់ធ្ងរហួសហេតុរបស់សាធារណរដ្ឋបារាំង ដែលនៅពេលបោះបង់ការគ្រប់គ្រងអាណានិគមនៅលើទឹកដីកម្ពុជាក្រោម គួរតែប្រគល់មកឲ្យប្រទេសកម្ពុជាវិញយ៉ាងហោចណាស់ទឹកដីកម្ពុជាក្រោមចំនួន ៥០ ភាគរយដែលធ្លាប់ជាទឹកដីមួយផ្នែកនៃព្រះរាជាណាចក្រកម្ពុជាខ្មែរ ។

ចំពោះការសន្និដ្ឋានបែបនេះ ព្រះមហាវីរក្សត្របានលើកឡើងបីចំណុចនូវប្រវត្តិសាស្ត្រទឹកដីកម្ពុជាក្រោម ។

***ទីមួយ*** ៖ នៅពេលដែលកម្លាំងអាណានិគមបារាំងនៅឆ្នាំ ១៨៦០ បានធ្វើសង្គ្រាមដណ្តើមកម្ពុជាក្រោម (ដែលត្រូវហៅថា ទឹកដីកូសាំងស៊ីនដោយពួកបារាំង) ពេលនោះកងទ័ពខ្មែររបស់ព្រះអង្គឌួង និងបន្ទាប់មក ព្រះនរោត្តម និងកងទ័ពអណ្ណាមកំពុងតែប្រយុទ្ធគ្នា ។ កងទ័ពខ្មែរបានការពារប្រទេសរបស់ពួកគេ ដែលជាទឹកដីពិសិដ្ឋកម្ពុជាក្រោម ។ កងទ័ពខ្មែរបានប្រយុទ្ធជាមួយកងទ័ពចក្រភពអាណ្ណាមដែលចង់ដណ្តើមកាន់កាប់កម្ពុជា និងចាប់យកកម្ពុជាធ្វើជាទឹកដីចំណុះប្រទេសរបស់ពួកគេផ្ទាល់ ។

***ទីពីរ*** ៖ នៅពេលដែលបានសម្រេចធ្វើអាណានិគមលើទឹកដីកម្ពុជាក្រោម ហើយបានដាក់កម្ពុជាក្រោមជាទឹកដីអាណានិគម និងជាខេត្តមួយនៃរដ្ឋរបស់ពួកគេ ប្រទេសបារាំងបានបញ្ចប់ការប្រឈមមុខដាក់គ្នារវាងកងទ័ពខ្មែរនិងអាណ្ណាម សម្រាប់ការកាន់កាប់ទឹកដីកម្ពុជាក្រោម ។ ដូច្នេះប្រទេសបារាំងគឺជាអ្នកលួចកាន់កាប់ទី ៣ ដែលបានប្រឹងឥតបានការរំលោភទឹកដីកូសាំងស៊ីន ។

***ទីបី*** ៖ ជាមួយនឹងការលេចមុខឡើងរបស់អ៊ំហូ (ហូជីមិញ) ក្នុងនាមជាវីរបុរសជាតិនៃប្រជាជនវៀតណាម (ខាងជើង កណ្តាល និងខាងត្បូង) សាធារណរដ្ឋបារាំងបានគិតរារាំងហូជីមិញ និងកងទ័ពវៀតមិញរបស់គាត់មិនឲ្យដណ្តើមកាន់កាប់កូសាំងស៊ីន ។ ប្រទេសបារាំងបានគិតថា ដោយផ្តល់ឲ្យកូសាំងស៊ីននៅចក្រភពអាណ្ណាមនៃស្តេច បាវ ដាយ ប្រជាជនវៀតណាមខាងត្បូង នឹងដឹងគុណចំពោះចក្រភពអាយ៉ង ។ នេះគឺជាការគិតខុស ការបាត់បង់ទាំងស្រុងនូវចិត្តសាស្ត្រ និងការមិនដឹងអ្វីសោះ អំពីទិដ្ឋភាពជាសារវ័ននៃបញ្ហារបស់វៀតណាមនិងកម្ពុជា ។

នៅពេលថ្មី ៗ នេះ ព្រះមហាវីរក្សត្រហាក់ដូចជាបង្កើនការយកចិត្តទុកដាក់ជាខ្លាំងទៅលើ ការសរសេរអំពីបញ្ហាព្រំដែនកម្ពុជា ។ កាលពីប៉ុន្មានថ្ងៃមុននេះ ព្រះអង្គបានលើកឡើងពីការឈ្លានពានចូលព្រំដែនកម្ពុជាពីសំណាក់ប្រទេសជិតខាងគឺថៃ វៀតណាម និងឡាវ ។ ព្រះអង្គថែមទាំងមានព្រះរាជបន្ទូលទៀតថា កម្ពុជាកំពុងតែធ្វើអត្តឃាតខ្លួនឯង ដោយនិយាយថាកម្ពុជាមិនមានព្រំដែនច្បាស់លាស់ ។ ប៉ុន្តែលោក វ៉ា គឹមហុង ប្រធានគណៈកម្មាការព្រំដែនកម្ពុជាបានអះអាងអំពីកិច្ចប្រឹងប្រែង ដើម្បីជម្រុងឲ្យមានការបោះបង្គោលព្រំដែនឲ្យបានច្រើនជាមួយប្រទេសជិតខាង ៕

***អត្ថបទដកស្រង់ពីសារព័ត៌មានរស្មីកម្ពុជា***
***ថ្ងៃទី ២០ – ២១ ខែមីនា ឆ្នាំ ២០០៥***

# លិខិតអំពាវនាវរបស់ខ្មែរកម្ពុជាក្រោម

*-ជូនចំពោះ លោក កូហ្វី អាណាន់ អគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ។*
*-ជូនចំពោះ លោក ចច ដឺបល្យូប៊ូស ប្រធានាធិបតីនៃសហរដ្ឋអាមេរិក ។*
*-លោក ចូសែបបូរែល ផតែល្ស ប្រធាននៃសភាអឺរ៉ុប ។*

យើងខ្ញុំជាខ្មែរក្រោមនៅទូទាំងពិភពលោក សូមអំពាវនាវដល់លោកជាទីគោរព សូមលោកចាប់អារម្មណ៍ចំពោះអំពើឧក្រិដ្ឋកម្មបំបាត់ពូជសាសន៍ ដែលរដ្ឋាភិបាលវៀតណាមកំពុងធ្វើទៅលើជនជាតិខ្មែរកម្ពុជាក្រោមនៅប្រទេសវៀតណាមនាបច្ចុប្បន្ននេះ ។ ហេតុដូច្នេះហើយ យើងខ្ញុំសូមលោកមេត្តាជួយគាំទ្រ និងឧបត្ថម្ភដល់យើងខ្ញុំជាជនជាតិខ្មែរកម្ពុជាក្រោម កំពុងតស៊ូទាមទារសិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង ។

ចាប់តាំងពីវៀតណាម ទន្ទ្រានកាន់កាប់ដែនដីកម្ពុជាក្រោមរហូតមក ប្រជារាស្ត្រខ្មែរកម្ពុជាក្រោមរាប់លាននាក់ បានបង្ខំចិត្តភៀសខ្លួនចាកចោលមាតុភូមិដ៏ពិសិដ្ឋរបស់ខ្លួន ។ ចំណែករាប់ពាន់រាប់ម៉ឺននាក់ទៀត ត្រូវបានអាណានិគមវៀតណាមសម្លាប់រង្គាល ដុតទាំងរស់ចាប់ឃុំឃាំង និងធ្វើទារុណកម្មយ៉ាងព្រៃផ្សៃ ។

ក្រោយពីអាណានិគមបារាំង បានកាត់ទឹកដីកម្ពុជាក្រោមឲ្យទៅរដ្ឋាភិបាលយួននៅថ្ងៃទី ០៤ មិថុនា ឆ្នាំ ១៩៤៩ អាជ្ញាធរវៀត-ណាមមិនដែលគោរពសិទ្ធិខ្មែរកម្ពុជាក្រោមសោះឡើយ ។ សូម្បីតែសិទ្ធិមូលដ្ឋានក៏គ្មានដែរ ដូចជាសិទ្ធិបញ្ចេញមតិ សិទ្ធិរក្សាជំនឿសាសនាសិទ្ធិរក្សាទ្រព្យសម្បត្តិរបស់ខ្លួន និងសិទ្ធិរក្សាវប្បធម៌ប្រពៃណីរបស់ខ្លួន ពោលគឺអាជ្ញាធរយួន បានរឹបអូសទ្រព្យសម្បត្តិ និងដីធ្លីរបស់ជនជាតិខ្មែរកម្ពុជាក្រោម បង្ខំឲ្យជនជាតិខ្មែរក្រោមបោះបង់ជំនឿសាសនា បន្តគាបសង្កត់ និងកាប់សម្លាប់ព្រះសង្ឃខ្មែរ វត្តអារាម និងទីសក្ការៈត្រូវបំផ្លាញចោលជាបន្តបន្ទាប់ ។ អាជ្ញាធរយួន មិនអនុញ្ញាតឲ្យកូនចៅខ្មែរក្រោមរៀនសូត្រភាសា អក្សរសាស្ត្រ និងប្រវត្តិសាស្ត្ររបស់ខ្លួនសោះឡើយ ។

ឧក្រិដ្ឋកម្មដែលរដ្ឋាភិបាលយួនបានបង្កឡើង ដើម្បីបំផុតពូជខ្មែរកម្ពុជាក្រោម មានដូចតទៅ ៖

១-កំឡុងឆ្នាំ ១៩៤៥ ក្នុងសង្គ្រាមលោកលើកទី ២ ជនជាតិខ្មែរកម្ពុជាក្រោមរាប់ម៉ឺននាក់ ត្រូវចាប់ដុតទាំងរស់ដោយពួកកុម្មុយនិស្តយួន ។

២-ពីឆ្នាំ ១៩៧៦ ដល់ ១៩៧៩ ជនជាតិខ្មែរកម្ពុជាក្រោមមានចំនួនរាប់ពាន់នាក់ នៅគ្រប់ខេត្តនៃដែនដីសណ្តទន្លេមេគង្គ ត្រូវបានសម្លាប់ដោយអាជ្ញាធរយួន ។

៣-នៅឆ្នាំ ១៩៧៨ អាជ្ញាធរយួនបានរឹបអូសទ្រព្យសម្បត្តិហើយបណ្តេញជនជាតិខ្មែរក្រោមរាប់សែននាក់ នៅខេត្តមាត់ជ្រូក និងបារ៉ាជូ ឲ្យចាកចេញពីស្រុកភូមិរបស់ខ្លួនទៅរស់នៅក្នុងព្រៃជ្រៅ ហៅថាតំបន់សេដ្ឋកិច្ចថ្មី ។ បន្ទាប់ពីនោះ អាជ្ញាធរយួនបានយកជនជាតិយួនឲ្យមករស់នៅក្នុងស្រុកភូមិខ្មែរជំនួសវិញ ។

៤-ពីឆ្នាំ ១៩៨៤ ដល់ ១៩៩០ អាជ្ញាធរយួនបានសម្លាប់រង្គាល ចាប់ឃុំឃាំង និងធ្វើទារុណកម្មទៅលើជនជាតិខ្មែរកម្ពុជាក្រោមរាប់ពាន់នាក់នៅខេត្តព្រះត្រពាំង (ត្រាវិញ) និងឃ្លាំង... ។ ក្នុងនោះក៏មានមន្ត្រីសង្ឃជាន់ខ្ពស់ ព្រះនាម គឹម តុក ចើង រួមជាមួយនឹងព្រះសង្ឃច្រើនរយអង្គទៀត ត្រូវបានធ្វើគត់យ៉ាងព្រៃផ្សៃ ។

៥-នៅខែកក្កដា ឆ្នាំ ២០០២ ព្រះតេជគុណ ឡឹម ខេន គង់នៅវត្តទឹកល្អក់ ស្រុកវីធី ខេត្តព្រែកឫស្សី (កឹនថឺ) ក៏ត្រូវបាន គេលួចធ្វើគត់យ៉ាងអាថ៌កំបាំងដែរ ។

រហូតដល់សព្វថ្ងៃនេះ រដ្ឋាភិបាលយួននៅតែបន្តអំពើរំលោភសិទ្ធិមនុស្សចំពោះជនជាតិខ្មែរកម្ពុជាក្រោមដដែល ជាក់ស្តែង គឺនៅខេត្តឃ្លាំង ជនជាតិខ្មែរកម្ពុជាក្រោមមានចំនួនបីពាន់នាក់ កំពុងរងទុក្ខដោយពិការភ្នែក ។ រដ្ឋាភិបាលយួនមិនដែលចាត់វិធានការណាមួយដើម្បីជួយសង្គ្រោះជនរងគ្រោះទាំងនោះឡើយ ពោលគឺដរាបណាអាណានិគមយួននៅតែវត្តមាន ដរាបនោះជនជាតិខ្មែរក្រោមនៅតែរងទុក្ខវេទនាឥតពេលល្ហែ ។

យើងខ្ញុំសូមអំពាវនាវ សូមឲ្យលោកមេត្តាជួយគាំទ្រ និងឧប-ត្ថម្ភដល់យើងខ្ញុំជាជនជាតិខ្មែរកម្ពុជាក្រោម ក្នុងបុព្វហេតុតស៊ូទាមទារសិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង ។ នៅពេលដែលយើងខ្ញុំបានសម្រេចនូវគោលបំណង សម្រេចវាសនាខ្លួនដោយខ្លួនឯងបានហើយនោះ ទើបយើងខ្ញុំទទួលបាននូវសិទ្ធិសេរីភាពជាមូលដ្ឋានដ៏ពិតប្រាកដដូចមនុស្សជាតិនានានៅលើពិភពលោកដែរ ។ម្យ៉ាងទៀត ក៏ដើម្បីរក្សាសន្តិភាព និងស្ថេរភាពនៅក្នុងប្រទេសយួន ក៏ដូចជានៅតំបន់ជិតខាង ។

*សូមទទួលសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ពីយើងខ្ញុំ !*
*ប្រជាពលរដ្ឋខ្មែរក្រោម*

# ពុទ្ធបរិស័ទនៅគ្រប់ទិសទីចូលរួមកសាងវត្តសាមគ្គីរង្សី

បន្ទាប់ពីអគ្គិភ័យ បានបង្កមហន្តរាយដល់វត្តសាមគ្គីរង្សី ដែលស្ថិតនៅសង្កាត់ស្ទឹងមានជ័យ ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ នៅថ្ងៃទី ០៩ កុម្ភៈ នោះមក គេបានឃើញបុណ្យផ្កាពីរប្រារព្ធឡើងភ្លាម ៗ នៅព្រះរាជាណាចក្រកម្ពុជា ។

បុណ្យផ្កាសាមគ្គីមួយ បានប្រារព្ធធ្វើនាថ្ងៃទី ១៩ កុម្ភៈ នាសាលាឆទានខ្មែរកម្ពុជាក្រោម ភូមិសាមគ្គី ដោយមានសប្បុរសជនចូលរួមបំពេញកុសលប្រមាណជាង ៥០០ នាក់នោះ លោក ច័ន្ទ សុខា ជាប្រធានគណៈកម្មការសាលាឆទានខ្មែរកម្ពុជាក្រោម និងជាសាមីដើមបុណ្យបានឲ្យដឹងថា "កន្លងមកសាលាឆទានលោកក៏ធ្លាប់បានធ្វើបុណ្យផ្កាជារឿយៗ តែចំណែកបុណ្យផ្កាមួយនេះសំខាន់ណាស់ ដែលត្រូវរួមគ្នាជួសជុលនិងកសាងភ្លាម ៗ នូវទីសេនាសនៈដែលបានខូចខាតដោយអគ្គិភ័យ ធ្វើឲ្យព្រះសង្ឃជាច្រើនអង្គគ្មានកន្លែងគង់ ពុទ្ធបរិស័ទគ្មានឧបដ្ឋានសាលាដើម្បីប្រារព្ធពិធីបុណ្យទានផ្សេង ៗ ។

បុណ្យផ្កាសាមគ្គីមួយទៀត ត្រូវបានប្រារព្ធធ្វើនៅថ្ងៃទី ២០ កុម្ភៈ ក្នុងបរិវេណវត្តសាមគ្គីរង្សី ដោយមិត្តសមាគមខ្មែរកម្ពុជាក្រោម ដែលមានសប្បុរសជនចូលរួមចាប់មគ្គផលពីគ្រប់មជ្ឈដ្ឋាន ។ លោក ថាច់ សាង នាយករងប្រតិបត្តិមិត្តសមាគមខ្មែរកម្ពុជាក្រោម និងជាសាមីដើមបុណ្យផងនោះ លោកមានប្រសាសន៍ក្នុងឱកាសបុណ្យផ្កានេះថា វត្តសាមគ្គីរង្សីពិតមែនតែជាវត្តថ្មី និងតូចមែន តែវត្តនេះធំណាស់សម្រាប់ពុទ្ធបរិស័ទខ្មែរក្រោម ព្រោះវត្តនេះជាមជ្ឈមណ្ឌលរបស់ខ្មែរកម្ពុជាក្រោមនៅកម្ពុជា ដែលខ្មែរក្រោមតែងតែពឹងពាក់ទីនេះប្រារព្ធពិធីបុណ្យជាតិរបស់ខ្លួន ដូចជាទិវាបារាំងកាត់ទឹកដីកម្ពុជាក្រោមទៅឲ្យយួន (០៤ មិថុនា ១៩៤៩) ដែលខ្មែរក្រោមប្រារព្ធធ្វើឡើងមុនដំបូងបំផុតក្នុងឆ្នាំ ២០០១ ក្រោមការរៀបចំរបស់សមាគមព្រះសង្ឃខ្មែរកម្ពុជាក្រោម ដែលមានព្រះតេជគុណ យឿង សិន ជាប្រធាន គឺនៅវត្តសាមគ្គីរង្សីនេះឯង ។ ហើយទោះជាវត្តមិនត្រូវរងអគ្គិភ័យក៏ដោយក៏យើងបានសាមគ្គីគ្នាខិតខំកសាង ឲ្យល្អថែមទៀតដែរ តែសម្រាប់ពេលនេះ យើងត្រូវតែខិតខំចំណាយកម្លាំងកាយចិត្តជាងពេលណា ៗ ទាំងអស់ ។

លុះមកដល់ថ្ងៃទី ២៦ កុម្ភៈ កន្លងទៅនេះពុទ្ធបរិស័ទខ្មែរនៅកម្ពុជាក្រោម និងបរទេស ក៏បានផ្ញើថវិកាមួយចំនួន និងសេចក្តីសោកស្តាយក្រៀមក្រំ តាមរយៈលោក ត្រឹង ម៉ាន់រិន នាយកផែនការសហព័ន្ធខ្មែរកម្ពុជាក្រោម រួមដំណើរដោយលោក ថាច់ ដារ៉ា សមាជិកសហព័ន្ធទៅពីប្រទេសកាណាដា និងលោក ថាច់ ជាង សមាជិកសហព័ន្ធទៅពីប្រទេសអូស្ត្រាលី ចូលរួមបំពេញកុសលកសាងវត្តសាមគ្គីរង្សី ព្រមទាំងចូលរួមរំលែកសេចក្តីក្រៀមក្រំនៃពុទ្ធបរិស័ទចំណុះជើងវត្តសាមគ្គីរង្សីជាអនេកកប្បការ ។

បន្ទាប់មកនៅថ្ងៃទី ០៣ មីនា ព្រះសុមេធាធិបតី ទេព វង្ស សម្តេចព្រះសង្ឃរាជគណៈមហានិកាយ នៃព្រះរាជាណាចក្រកម្ពុជា អមព្រះរាជដំណើរដោយមន្ត្រីរាជការជាច្រើនរូបទៀត បានពាំនាំនូវចតុបច្ច័យ ដែលជាព្រះរាជអំណោយរបស់សម្តេចផ្ទាល់ និងជារបស់



ព្រះពុទ្ធបដិមាវត្តសាមគ្គីរង្សី នៅរាជធានីភ្នំពេញ ដែលត្រូវកម្លោច ដោយអគ្គិភ័យ

មន្ទីរធម្មការក្រុង ទៅប្រទាន និងប្រគេន ជូនដល់ព្រះសង្ឃវត្តសាមគ្គីរង្សី ផងដែរ ។

សម្តេចទ្រង់មានព្រះរាជបន្ទូលសំណេះសំណាល សួរសុខទុក្ខ រំឭកដល់ព្រះសង្ឃ ព្រមទាំងពុទ្ធបរិស័ទចំណុះជើងវត្តថា "យើងត្រូវរួបរួមសាមគ្គីគ្នាជាធ្លុងមួយ ដើម្បីពង្រីកនូវវិស័យព្រះពុទ្ធសាសនារបស់យើង ។ យើងសាមគ្គីរស់ បើយើងបែកបាក់សាមគ្គីស្លាប់" ។

ដោយឡែកនៅថ្ងៃទី ០៤ មីនា កាកបាទក្រហមរាជធានីភ្នំពេញ បាននាំយកនូវចតុបច្ច័យ ទៅប្រគេនដល់ព្រះសង្ឃវត្តសាមគ្គីរង្សី ហើយក្រៅពីការសំដែងនូវសេចក្តីសោកស្តាយចំពោះសមិទ្ធផលដែលត្រូវបានបាត់បង់ដោយអគ្គីភ័យ នោះលោកតំណាងកាកបាទក្រហមក៏បានរំឭកផងដែរនូវប្រវត្តិដ៏ជូរចត់របស់ខ្មែរថា "ខ្មែរយើងអភ័ព្វណាស់ ព្រោះបរទេសជិតខាងចេះតែលេបត្របាក់ទឹកដីរបស់យើង តែអ្វីដែលយើងចាំមិនភ្លេច ហើយឈឺចាប់បំផុតនោះ គឺព្រឹត្តិការណ៍ឆ្នាំ ១៩៤៩ ជាឆ្នាំដែលអាណានិគមនិយមបារាំងកាត់ទឹកដីខ្មែរទៅឲ្យយួនធ្វើអាណានិគមបន្តរហូតដល់សព្វថ្ងៃ ហើយទឹកដីខ្មែរដែលបារាំងកាត់ផែនទីទៅឲ្យយួននោះ គឺជាទឹកដីកម្ពុជាក្រោមសព្វថ្ងៃនេះឯង" ។

ទន្ទឹមនឹងបណ្តាអង្គភាពពុទ្ធបរិស័ទនានា ក៏នៅមានពុទ្ធបរិស័ទ សប្បុរសជនជាច្រើនរូប ច្រើនអង្គទៀតបានពាំនាំនូវចតុបច្ច័យជួយឧបត្ថម្ភ កសាងវត្តសាមគ្គីរង្សី ផងដែរ ។

ជាមួយនឹងការចូលរួមរំលែកទុក្ខ និងការចូលរួមឧបត្ថម្ភកសាងវត្តពីសំណាក់ពុទ្ធបរិស័ទ សប្បុរសជនពីគ្រប់មជ្ឈដ្ឋាននោះ ព្រះតេជគុណ យឿង សិន ប្រធានសមាគមព្រះសង្ឃខ្មែរកម្ពុជាក្រោម និងជាព្រះចៅអធិការវត្តសាមគ្គីរង្សី ព្រមទាំងព្រះសង្ឃ ពុទ្ធបរិស័ទចំណុះជើងវត្តទាំងមូល បានសំដែងនូវការអបអរសាទរ និង ជូនពរដល់សាមីដើមទានជាអនេកប្បការ ដោយធានាថានឹងកសាងវត្តសាមគ្គីរង្សី មួយឲ្យមានសោភ័ណភាព រចនាសម្ព័ន្ធល្អតាមពុទ្ធវចនៈ ពុំឲ្យឃ្លាតឃ្លាតវាតឡើយ ៕

VOKK

# ឆ្មាំព្រំដែនយួនធ្វើទុក្ខដល់ព្រះសង្ឃខ្មែរកម្ពុជាក្រោម


Mẫu quyết định số 07

CỘNG HÒA XÃ HỘI CHỦ NGHĨA VIỆT NAM
Độc lập - Tự do - Hạnh phúc

Số: …/QĐ-XPHC … ngày … tháng 02 năm 2005

QUYẾT ĐỊNH
XỬ PHẠT VI PHẠM HÀNH CHÍNH
VỀ …

Căn cứ Pháp lệnh Xử lý vi phạm hành chính ngày 02 tháng 7 năm 2002;
Căn cứ Điều … Nghị định qui định xử phạt vi phạm hành chính trong lĩnh vực …

Căn cứ Biên bản vi phạm hành chính do … lập hồi … giờ … ngày … tháng 02 năm 2005 tại …
Tôi, … ; Chức vụ: …
Đơn vị: …

QUYẾT ĐỊNH:

**Điều 1**. Xử phạt vi phạm hành chính đối với:
Ông (bà)/tổ chức: …
Nghề nghiệp (lĩnh vực hoạt động): …
Địa chỉ: …
Giấy chứng minh nhân dân số/Quyết định thành lập hoặc ĐKKD: …
Cấp ngày: … tại …
*Với các hình thức sau:*
1- Hình thức xử phạt chính:
Cảnh cáo/phạt tiền với mức phạt là: … đồng. (Viết bằng chữ: …)
2- Hình thức phạt bổ sung (nếu có):
1. Tước quyền sử dụng giấy phép, chứng chỉ hành nghề: …
2. Tịch thu tang vật, phương tiện được sử dụng để vi phạm hành chính gồm: …
3- Các biện pháp khắc phục hậu quả (nếu có): …

*កំណាត់ហេតុឆ្មាំព្រំដែនយួនដកហូតសម្ភារៈរបស់ភិក្ខុ សឺន វិត*

ឆ្មាំព្រំដែនយួនជារឿយ ៗ តែងចាប់ និងរឹបអូសយកនូវក្បួនខ្នាត សៀវភៅ ឯកសារ គម្ពីរធម៌របស់ពុទ្ធបរិស័ទខ្មែរ ដែលនាំចូលមកកម្ពុជាក្រោមជានិច្ច ។

ថ្មី ៗ នេះព្រះសង្ឃ ១ ព្រះអង្គ ព្រះនាម សឺន វិត គង់នៅវត្តដើមពោន ឃុំស្នេក យួនហៅ វិញត្រិច ទីរួមខេត្តពលលាវ បានត្រូវឆ្មាំព្រំដែនយួននៅច្រកព្រំដែនខេត្តពាម (ហាទៀង) កម្ពុជាក្រោម និងខេត្តកំពតកម្ពុជាកណ្តាល ចាប់បង្ខាំងព្រះអង្គអស់ ៣ ថ្ងៃ ចាប់ពីថ្ងៃទី ១៧ ដល់ ១៩ កុម្ភៈ ឆ្នាំ ២០០៥ ព្រមទាំងប្រើពាក្យប្រមាថ ជេរស្តីព្រះអង្គជាច្រើនប្រការ ។

តាមកំណត់ហេតុ និងពាក្យបណ្តឹងរបស់ព្រះសង្ឃរងគ្រោះ បានឲ្យដឹងថា ឆ្មាំព្រំដែនយួនរឹបអូសយកបរិក្ខារ ឯកសារ និងសៀវភៅរបស់ព្រះអង្គរួមមាន ៖

១-VCD ចម្រៀងខ្មែរក្រោម ១ បន្ទះ ។

២-ព្រឹត្តិបត្រកម្ពុជាក្រោម ចំនួន ១២ ក្បាល ។

៣-សៀវភៅពង្សាវតាខ្មែរ ចំនួន ១ ក្បាល ។

៤-ឯកសារសេចក្តីថ្លែងការណ៍របស់សហព័ន្ធ នៅលើវេទិកាអចិន្ត្រៃយ៍ជនជាតិដើមឆ្នាំ ២០០៤ ចំនួនមួយចប់ គឺ ៧ ច្បាប់ ។

៥-រូបថតផ្ទាល់ព្រះអង្គ ដែលថតនៅកម្ពុជាក្រោម ចំនួន ៩ សន្លឹក ។

៦-សៀវភៅទិន្នានុប្បវត្តិ ចំនួន ១ ក្បាល ។

តាមថេរដីការបស់ព្រះសង្ឃរងគ្រោះ បានឲ្យដឹងទៀតថា សូម្បីតែផ្លាកសញ្ញា ដែលបិទជាប់នឹងដបប្រេងខ្យល់ បោះពុម្ពជាអក្សរខ្មែរថា "សមាគមព្រះសង្ឃខ្មែរកម្ពុជាក្រោម" នោះ ក៏ត្រូវឆ្មាំព្រំដែនយួនបកចោលទាំងអស់ដែរ ។ លុះព្រះអង្គនិមន្តមកដល់វត្តកំណើត (វត្តដើមពោន) ព្រះអង្គត្រូវបានសមត្ថកិច្ចនគរបាលយួនខេត្តពលលាវ ហៅព្រះអង្គទៅសួរចម្លើយជាច្រើនលើកច្រើនសារ អំពីអ្វីដែលព្រះអង្គនិងខ្មែរក្រោមបានធ្វើនៅកម្ពុជា ។

ព្រះសង្ឃរងគ្រោះមានថេរដីកាបន្តថា ព្រះអង្គបាននិមន្តទៅភ្នំពេញ ដើម្បីសិក្សាភាសាបាលី និងធម្មវិន័យតាំងពីឆ្នាំ ២០០២ មកម្ល៉េះហើយនេះមិនមែនជាលើកទី ១ ទេ ដែលអាជ្ញាធរយួនឃុំឃាំងព្រះអង្គ គឺកាលពីចុងឆ្នាំ ២០០៣ ព្រះអង្គធ្លាប់ត្រូវបានអាជ្ញាធរមូលដ្ឋានយួនបំពានមកលើព្រះអង្គបែបនេះម្តងរួចមកហើយ ។ ហើយលើកនេះ ព្រះអង្គបាននាំមកជាមួយនូវឯកសារ ព្រឹត្តិបត្រសហព័ន្ធមកស្រុកកំណើត ដើម្បីផ្សព្វផ្សាយឲ្យបងប្អូនខ្មែរក្រោមនៅក្នុងស្រុកបានយល់ បានដឹងអំពីសិទ្ធិមនុស្ស និងសកម្មភាពរបស់បងប្អូនខ្មែរក្រោមនៅក្រៅស្រុក ព្រោះភាគច្រើន បងប្អូនខ្មែរក្រោមយើងនៅក្នុងស្រុកពុំទាន់យល់ច្បាស់នូវសិទ្ធិរបស់ខ្លួននៅឡើយ ហើយបងប្អូនទាំងនោះទៀតសោត គេចង់ដឹងណាស់អំពីសកម្មភាពរបស់បងប្អូនខ្មែរក្រោមនៅក្រៅស្រុក ។

ទាក់ទិននឹងបញ្ហាថា ហេតុអ្វីបានជាព្រះសង្ឃខ្មែរក្រោមនិយមនិមន្តឆ្លងទៅរៀននៅកម្ពុជានោះ ព្រះសង្ឃរងគ្រោះបានបំភ្លឺថា នៅកម្ពុជាក្រោមសព្វថ្ងៃយួនគាបសង្កត់តឹងតែងណាស់ មិនអនុញ្ញាតឲ្យខ្មែរក្រោមរៀនសូត្រនូវចំណេះដឹងល្អ ៗ ពីប្រវត្តិសាស្ត្រ ភូមិសាស្ត្រខ្មែរក្រោមនោះទេ ។

តាមប្រភពព័ត៌មានពីប្រជាជន នៅតាមបណ្តោយព្រំដែនកម្ពុជា-កម្ពុជាក្រោមបានឲ្យដឹងថា ជារឿយ ៗ ពួកគេតែងឃើញឆ្មាំព្រំដែនយួន ចាប់យកឯកសារ សៀវភៅ ក្បួនខ្នាត និងគម្ពីរធម៌ពីព្រះសង្ឃ និងប្រជាពលរដ្ឋខ្មែរក្រោម តែអ្នកខ្លះព្រះសង្ឃខ្លះ ក៏សុខចិត្តលាក់ទុកនូវអំពីរលោភសិទ្ធិទាំងនេះរបស់យួនដោយក្តីឈឺចាប់ ។ ពួកគាត់បំភ្លឺបន្ថែមទៀតថា ពីរឆ្នាំកន្លងមកនេះ យើងឃើញថាធូរស្រាលបន្តិចហើយអំពីសកម្មភាពធ្វើទុក្ខបុកម្នេញដល់ព្រះសង្ឃ និងប្រជាពលរដ្ឋខ្មែរក្រោមឆ្លងដែន ពីសំណាក់ឆ្មាំព្រំដែនយួននោះ ។ ចំពោះករណីភិក្ខុ សឺន វិត បើដូចពីឆ្នាំមុននោះ ប្រាកដជាត្រូវអាជ្ញាធរយួនចាប់បន្សឹក និងដាក់គុកមិនខានឡើយ ។

តាមប្រសាសន៍របស់លោកអ៊ំ ថាច់ ដែលជាជនកុម្មុយនិស្តជើងចាស់ម្នាក់បានបញ្ជាក់ថា អាកប្បកិរិយាធូរស្រាលរបស់យួនចំពោះខ្មែរក្រោមនេះ មិនមែនយួនចិត្តល្អដោយឯកឯងនោះទេ គឺយួនខ្លាចត្រូវដំបងរបស់សហព័ន្ធខ្មែរកម្ពុជាក្រោម ដែលមានច្បាប់អង្គការសហប្រជាជាតិជាបង្អែកនោះឯង ៕ VOKK

# រឿងកំពប់តែអុង

អត្ថបទកំណាព្យនេះ ត្រូវបានរក្សាទុកអក្ខរាវិរុទ្ធ
តាមច្បាប់ដើមទាំងស្រុង

## សាស្ត្រាវត្តក្រូច – រៀបរៀងដោយសាស្ត្រាចារ្យ ឃឹន សុខ

**(តពីលេខមុន)**

១៤៤-រកឫកដោគជ័យ     ល្អល្អះប្រពៃ
ពេកពិតឥតហ្មង     ស្រេចបានពេលា
ដាក់ជាកន្លង     ស្តេចសោយរាជ្យគ្រង
ក្រុងកម្ពុជា ។

១៤៥-អស់មុកមន្ត្រី     ធំតូចផងក្តី
គង់គាលត្រៀបត្រា     ផ្គុំភ្លេងរងំ
សូរស័ព្ទសមគ្នា     ពលពាលអាសារ
សម្រាប់ច្រើនក្រៃ ។

១៤៦-លេងភ្លេងមហោស្រព នៅល្បែងផងគ្រប់
ជួបប្រាំពីរថ្ងៃ     ទើបអស់ព្រាហ្មព្រឹទ្ធ
បរោហិតសាយសៃ     ផ្គុំស័ង្ខជាញជ័យ
ថ្វាយព្រះនាម្នា ។

១៤៧-ឡើងព្រះនាមនាដ្ឋ សម្តេចព្រះបាទ
ឧទៃរាជា     គ្រប់គ្រងមន្ត្រី
សេណីសេណា     ក្រុងកម្ពុជា
បូរីរាជស្ថាន ។

១៤៨-រាស្ត្ររឹងសុកល     ភូមិភពមណ្ឌល
សប្បាយក្សេមក្សាន្ត     អង្គឥតសត្រូវ
ណានិងបៀតបាន     បទបុណ្យក្សត្រក្សាន្ត
គ្រប់គ្រងបូរី ។

១៤៩-ឯពញាយោមរាជ សៀមសុទ្ធឯងអាង
ជាធំធិបត្តី     បំរើពុទ្ធិចៅ
ចេញទៅរឹងខ្មី     អព្ភៃត្បែសក្តី
សឹងទៅទាំងអស់ ។

១៥០-អព្ភៃត្បែសនោះ     ទុកកូនមួយឈ្មោះ
ម៉្មាជាចោងប្រុស     ឲ្យនៅមើលផ្គុន
ថៃថ្មួនគ័បខុស     បទបងជាប្រុស
ខុសឆ្គងមើលគ្នា ។



យួនយកក្បាលខ្មែរធ្វើជាមុំចង្ក្រានកល់ដាំតែអុង

១៥១-ឯអង្គព្រះបាទ     សម្តេចនានាដ្ឋ
ឧទៃរាជា     គ្រប់គ្រងមហៃសី
បេតីស្នេហា     ឯបងឈ្មោះម៉្មា
ឲ្យជាធំធ្ងន ។

១៥២-ធ្វើជាព្រះអង្គ     ព្រះញាតិវង្ស
សាស័ក្តសមសួន     តែងទុកព្រះទ័យ
អាល័យស្មើខ្លួន     ឲ្យមើលថៃថ្មួន
ធំក្នុងបូរី ។

១៥៣-ឯលោកចៅហ្វារ ប៉ុកពិតជារា
ចាស់ណាស់ស្មារតី     និងគិតរាជការ
រក្សារបូរី     មិនបានបទក្តី
ជុនចាស់ជរា ។

១៥៤-ព្រះអណុជទាំងបី លោកឲ្យម្ត្រី
ទាំងបីអង្គារ     ចក្រីក្រហោម
យោមរាជរក្សា     បងលោកជរា
រក្សាមិនបាន ។

១៥៥-ចៅហ្វារប៉ុកនៅ     យូរបន្តិចទៅ
ជុនចាស់ចាកស្ថាន     ខ្សិនក្ស័យជីវិត

អស់ឥតវិញ្ញាណ ស្ដេចធ្វើបុណ្យទាន
បរបូណ៌ប្រពៃយ ។
១៥៦-ធ្វើមេនមាន់ដប់ ហាក់ដូចព្រះសព
ព្រះបិតាថ្លៃ ធ្វើបុណ្យឲ្យទាន
មិនមានសង្ស័យ ស្ដេចទុកព្រះទ័យ
ស្មោះស្មើបិតា ។
១៥៧-ដំណើរក្រោយនោះ ចៅហ្វាវប៉ុកលុះ
ក្សិនក្ស័យជន្មា ស្ដេចតាងឈ្មោះនាំន្ត
ឲ្យកាន់កិច្ចការ ធ្វើជាចៅហ្វារ
រក្សារាស្ត្រផង ។
១៥៨-យូរបន្តិចទៅ ព្រះអណ្ដុជហៅ
អង្គស្ងួននោះហោង ស្ដេចអាក់ងន់ឯង
ទាស់ទែងនឹងបង បន្តិចទៅហោង
ហេតុព្រោះបទស្រី ។
១៥៩-ខានពុំបានគាល់ ព្រះរាមរៀងរាល់
ខានជាជួបចាប់ គំរប់ថ្ងៃបី
ទើបឡើងទៅខ្មី កាន់ព្រះរៀមរ័ក ។
១៦០-ព្រះរាមស្ដេចយល់ ព្រះអាណុជដល់
ឡើងលើដំណាក់ ស្ដេចមានបន្ទូល
សារសួរស្មោះស្ម័គ្រ ផ្អូនមានបើអាក់
អន់អ្វីនឹងបង ។
១៦១-បានមិនមកគាល់ សព្វថ្ងៃរៀងរាល់
ដូចដោយមួយដង បើប្អូនអន់អាក់
ថ្នមថ្នាក់ម្ដេចម្ដង ប្អូនប្រាប់មកបង
ឲ្យបានដឹងជាក់ ។
១៦២-ឯព្រះអាណុជ ស្ដេចស្ដាប់ចោទចុច
ចង់ដឹងចិត្តជាក់ ចូលទៅថាខ្ញុំ
ពិតពុំអន់អាក់ និងព្រះរាមរ័ក
អ៊ែកតើបទអ្វី ។
១៦៣-ទូលទៅដំណោះ អ៊ែកអន់ក្នុងពោះ
ពិតពុំស្រដី ស្រេចហើយម្ទីម្នា
លុះលាបាខ្មី ទៅដល់ទាល់ទី
លំនៅអាត្មា ។
១៦៤-ស្ងាត់ហើយជុំនំ នាម៉ឺនចាស់ទុំ
តែងទុកចិន្តា នៅអស់មហាត្លឹក
ពួកពលអាសារ ថាអញនោះណា
នៅនេះមិនបាន ។
១៦៥-ចូរឯងរាល់គ្នា រួសរៀបអាត្មា
គ្រប់គ្រឿងប្រុងប្រាណ ប្រដាប់គ្រឿងសេះ
យុបនេះចងអាន អាទ្រាតស្ងាត់បាន
ចចាកចេញខ្មី ។
១៦៦-អញចង់ចទៅ ត្រេចត្រង់សំដៅ
ក្រុងទេពបូរី បង្គំព្រះចៅ
និងនៅនេះថ្មី ទោស្បតែពីស្រី
ស្រដីមិនបាន ។
១៦៧-ពួកពលអាសា ស្ដាប់ស្ដេចត្រាសថា
ដូច្នេះស្មោះស្មាន យកសេះចងគ្រឿង
រុងរឿងស្រេចបាន ស្ដេចចេញចាកស្ថាន
បន្ទាយវាំងចាស់ ។
១៦៨-ស្ដេចយាងទាំងយុប ពិតពុំឈរឈប់
ស្រូតរូតរហ័ស អាធ្រាតយប់ជ្រៅ
ចេញទៅភ្លឺច្បាស់ ទើបស្ដេចត្រេកត្រាស់
ឲ្យបទឈប់នៅ ។
១៦៩-សំរាកជើងពល បរិភោគស្កប់ស្កល់
ស្រេចហើយទើបទទៅ ស្ដេចគង់អស្សពារ
លេលាសំដៅ ដើរតាមដោយផ្លូវ
ទៅទេពបូរី ។
១៧០-ព្រឹកព្រាងសូរិយា ឧទៃយរាជា
បានជ្រាបសេចក្ដី ថាអាណុជក្ស័ត្រ
រត់បាត់ពិតពៃ ដំណាក់នោះខ្មី
ស្ដេចត្រាស់ប្រើឲ្យ ។
១៧១-ហៅមហាអការ កែនពលម្ទីម្នា
លើកតាមដោយក្រោយ ថាបើទាន់ក្ស័ត្រ
ហើយឃាត់កុំឲ្យ ស្ដេចទៅមុខឲ្យ
មកក្រោយវិញផ្ទាត់ ។
១៧២-ឯមហាអការ ស្រូតរូតដោយម្ទីម្នា
ដល់ពោធិសាត់ ទៅទាន់ស្ដេចគង់
ក្នុងខេត្តនោះផ្ទាត់ ទើបឯមហាក្សត្រ
បន្ទឹងវិញថា ។
១៧៣-ឯងមករកអ្វី តាមអញនោះថ្មី

ទើបមហាអការ ក្រាបទូលទៅវិញ
អញខ្ញុំនោះណា ព្រះរាមរាជា
ត្រាស់ប្រើឲ្យមក ។

១៧៤-អញ្ជើញស្ដេចទៅ ទីស្ថានលំនៅ
កុំទៅបាងកក ព្រះរាមរាជា
ត្រាស់ថាឲ្យមក ឲ្យខ្ញុំខំយក
ស្ដេចទៅឲ្យបាន ។

១៧៥-ទើបស្ដេចត្រាស់ថា ឆ្មោះមហាអការ
ចិត្តឯងនោះហាន មកចាប់ចងអញ
នោះមិញមិនខាន ទើបយកទៅបាន
ដូចដោយបង្គាប់ ។

១៧៦-ពះ ! ក្មេងអស់គ្នា ចាប់មហាអការ
នោះយកទៅកាប់ ដោយក្បាលឲ្យបាន
នៅស្នាមនោះនា ចាប់កុំឲ្យវាធ្លាប់
មើលងាយអង្គស្ដេច ។

១៧៧-មហាត្លឹកទាំងឡាយ ចូលចាប់ប្រញាយ
ចាប់ចងប្រានស្រេច ហើយនាំយកទៅ
ក្រៅកាប់កដាច់ ដោតក្បាលបានស្រេច
តាមស្ដេចបង្គាប់ ។

១៧៨-ទើបស្ដេចលីលា ឡើងលើអស្សពារ
គុនគូរស្រេចស្រាប់ ស្រូតស្រូវចេញចរ
បរជាប្រញាប់ ប្រញាប់ឆ្មៀងឆាប់
ដល់ដីបាងកក ។

១៧៩-ចូលថ្វាយបង្គំ គាល់ព្រះចៅធំ
ទ្រង់សារសួមក ថាចៅអង្គសួន
ជូនបើមករក ឬមានបើឆ្លក
ទាស់ទែងនឹងគ្នា ។

១៨០-រីឯអង្គសួន ស្ដាប់ស្ដេចសួរខ្លួន
ពិតពុំមុសារ ក្រួញក្រាបទូលទៅ
ព្រះចៅយុទ្យា អស់អាតិតា
ស្ដេចស្ដាប់ស្ងៀមនៅ ។

១៨១-ដំណើរនៃនៅ សង្ខេបទុកស្លេះ
នឹងនិទានទៅ តពីដើមដាន
ក្សត្រក្សាន្តចោមចៅ ឧទៃរាជា
គ្រងរាជរដ្ឋា ។

១៨២-យូរយល់បន្តិច ទៀងទើបសម្ដេច
បទចៅពញាធម្មា នាមដើមឈ្មោះតី
ជាតិជាជិតា បង្កើតក្សត្រា
ឧទៃរាជស្មោះ ។

១៨៣-មានមួយទិវា សម្ដេចចៅពញា
ដីទូលជំពាក់ ថាដ្បិតឧកញា
ក្រឡាហោមឈ្មោះ ឯកឯងពុំស្មោះ
គិតក្បត់ក្សត្រា ។

១៨៤-ពីនិងចក្រី បែនបានស្រដី
គុបគិតនិងគ្នា ថាបើស្ដេចឆ្វេស
ប្រហែសកាលណា គេគិតព្រមគ្នា
លព្វលុកលុះបាន ។

១៨៥-បទពំនោលនៅនិទាន ឯអង្គក្សត្រក្សាន្ត
ព្រះបាទឧទៃរាជា ។

១៨៦-ស្ដេចស្ដាប់សាសាប់វាចា ពាក្យពីជិតា
ទូលទៅដូច្នេះក្រោធក្រៃ ។

១៨៧-ខំអត់សង្កត់ព្រះទ័យ ពុំថ្លែងសម័យ
ដោយន័យគំនិតគិតនោះ ។

១៨៨-ស្ដេចគិតគំនិតក្នុងពោះ បើក្បត់ដូច្នេះ
វានោះនិងទុកធ្វើអ្វី ។

១៨៩-គួរកាប់សម្លាប់ទៅខ្មី ក្រហោមចក្រី
អញតាំងជាថ្មីឡើងបាន ។

១៩០-គិតស្រេចសម្ដេចក្សត្រក្សាន្ត បើកបន្ទូលថ្កាន
សម្ដេចតីជាជិតា ។

១៩១-ឲ្យជ្រើសរើសរកសេណា ជឿចិតចិន្ដា
ម្នីម្នាគិតការឲ្យឆាប់ ។

១៩២-សម្ដេចចៅពញាបានស្ដាប់ ស្ដេចត្រាស់ប្រើប្រាប
បង្គាប់អង្គឯងដូច្នេះ ។

១៩៣-ក្រាបលាម្នីម្នាចរចាក ចុះចេញមកស្មោះ
ហៅទូនផនោះមកគិត ។

១៩៤-ទូនផ្ងាម្នីម្នាចូលជិត បៀតបានដល់គិត
ខំឃាតជិតខ្សឹបប្រាប់ថា ។

១៩៥-ដូចនៃព្រទ័យក្សត្រា ត្រាស់ប្រើអាត្មា
គិតការជាឆាប់ប្រញាប់ ។

(**នៅមានត**)

# ប្រវត្តិ "វត្តចូឡាមណីចេតិយ" ឬ "វត្តចេតិយ"

វត្តចេតិយជាវត្តបុរាណមួយ សាងឡើងក្នុងពុទ្ធសករាជ ២០៣១ គ្រិស្តសករាជ ១៤៨៨ បើគិតមកដល់បច្ចុប្បន្ននេះ មានអាយុ ៥១៧ ឆ្នាំ ហើយវត្តនេះស្ថិតនៅភូមិត្នោតលៃ ឃុំចេត្តិយ៍ ស្រុកថ្កូវ ខេត្តព្រះត្រពាំង កម្ពុជាក្រោម ។

បើយើងធ្វើដំណើរចុះពីខេត្តព្រះត្រពាំងទៅ វត្តនេះស្ថិតនៅខាងទិសនិរតីមានចម្ងាយផ្លូវប្រមាណ ២៧ គីឡូម៉ែត្រ ពីទីរួមខេត្ត ដោយឆ្លងកាត់ស្រុកចំនួន ៣ គឺស្រុកកំពង់ធំ បច្ចុប្បន្ន (ចូវថាញ់) ស្រុកផ្ទោរដាច់ បច្ចុប្បន្ន (កូវង៉ាង) និងស្រុកថ្កូវ បច្ចុប្បន្ន (ត្រាគូ) ។ តែបើតាមការស្រាវជ្រាវរបស់បុរាណវិទូជាតិវៀតណាមម្នាក់ឈ្មោះ វៀន វ៉ាន់តី ដែលគាត់បានដឹកនាំក្រុមអ្នកស្រាវជ្រាវមួយក្រុមមកពីហាណូយចុះទៅស្រាវជ្រាវនៅឆ្នាំ ១៩៩៤ គាត់អះអាងថា ៖ វត្តពោធិចូឡាមណីចេតិយ ឬ វត្តចេតិយ នេះកសាងឡើងតាំងពីសតវត្សរ៍ទី ១២ នៃគ្រិស្តសករាជមកម្ល៉េះ ហើយវត្តនេះមានចេតិយបុរាណមួយ មានបណ្តោយ និងទទឹង ១៤ ម៉ែត្របួនជ្រុង ។

ពេលនោះ ពួកគាត់មួយក្រុមមានតាំងពីអាជ្ញាធរគ្រប់លំដាប់ថ្នាក់ គឺមន្ត្រីថ្នាក់ខេត្ត ស្រុក ឃុំ មកសុំប្រជាពុទ្ធបរិស័ទខ្មែរក្នុងចំណុះជើងវត្ត ដើម្បីសុំធ្វើការជីកគាស់ស្តូបចេតិយនៅគ្រឹះខាងក្រោម ហើយគាត់ថា បើសិនជីកកំណាយទៅឃើញគ្រិះខាងក្រោមពិតជាកសាងនៅសតវត្សរ៍ទី ១២ តាមឯកសាររបស់គាត់ពិតប្រាកដមែននោះ ពួកគាត់នឹងរៀបចំឯកសារមួយជួយធ្វើការផ្សព្វផ្សាយ នូវវប្បធម៌របស់ខ្មែរយើង ហើយនឹងជួយកសាងចេតិយនៅទីនេះឲ្យវាមានសោភ័ណភាពល្អឡើងវិញ និងបានជាប្រយោជន៍សម្រាប់ទាក់ទាញភ្ញៀវទេសចរចូលមកទស្សនាពីវប្បធម៌របស់ខ្មែរទៀតផង ។ ប៉ុន្តែទោះជាក្រុមអ្នកស្រាវជ្រាវ និងអាជ្ញាធរវៀតណាមខិតខំស្នើសុំទទូចយ៉ាងណាក៏ដោយ ក៏ប្រជាពុទ្ធបរិស័ទក្នុងចំណុះជើងវត្ត មិនព្រមឲ្យគេជីកកកាយស្រាវជ្រាវដែរ ។ ដោយមានការខ្លាចបាក់បែកទីសារណដ្ឋានរបស់ដូនតាដែលគាត់បានកសាងទុកឲ្យកូនចៅសម្រាប់គោរពបូជា ហើយក៏បានពន្យល់ និងសូមកុំឲ្យអ្នកស្រាវជ្រាវធ្វើការគាស់ជីកកកាយធ្វើអី ពីព្រោះកន្លែងចេតិយនេះ គ្មានអ្វីសំខាន់សម្រាប់អ្នកបុរាណវិទូ និងអាជ្ញាធរមកធ្វើការស្រាវជ្រាវនោះទេ គឺគ្រាន់តែជាកន្លែងមួយសម្រាប់បញ្ចុះអដ្ឋិធាតុដូនតាពីបរមបុរាណប៉ុណ្ណោះ ហើយសព្វថ្ងៃនេះ ប្រជាពុទ្ធបរិស័ទនៅក្នុងចំណុះជើងវត្ត តែងតែទៅធ្វើការគោរពបូជាបង្សុកូលឲ្យជីដូនជីតាជារៀងរាល់ឆ្នាំ ។ បើសិនជារដ្ឋធ្វើការគាស់កកាយនោះ ពិតជាបាក់បែក រលំរលាយនៅទីកន្លែងគោរពបូរជារបស់ខ្មែរអស់ហើយ ។ ក្រោយពីពុទ្ធបរិស័ទបានធ្វើការពន្យល់ និងបកស្រាយអស់រយៈពេល ៥ ម៉ោង និង ៣០ នាទីរួចមក ក្រុមអាជ្ញាធរ និងអ្នកស្រាវជ្រាវរបស់វៀតណាមចំនួន ៣ ឡាន និងម៉ូតូជាច្រើនគ្រឿងទៀត បានត្រឡប់ទៅវិញពេល ដែលព្រះ អាទិត្យហៀបនឹងអស្តង្គត នោះដែរ ។

ម្យ៉ាងទៀត តាម ពាក្យដំណាលចាស់ ៗ ពី បុរាណ គាត់បាននិយាយ ប្រាប់ថា វត្តចេតិយនេះមាន ព្រះពុទ្ធរូបមួយអង្គ មានរិទ្ធិចេស្តាបារមីអស្ចារ្យណាស់ ពីព្រោះ កាលពីជំនាន់បារាំងសេសកាន់កាប់ ព្រះពុទ្ធរូបមួយអង្គនោះ បានផុសឡើង ហើយពុទ្ធបរិស័ទធ្វើការបញ្ចុះទៅវិញអស់រយៈពេលជាច្រើនសា ។ ប៉ុន្តែនៅពេលចុងក្រោយ ត្រូវតែតម្កល់ព្រះអង្គឲ្យគង់នៅលើបល្ល័ង្កជារៀងរហូតមកដល់ថ្ងៃនេះ ។ ជាមួយគ្នានេះដែរ នៅសម័យនោះ បើអ្នកណាមានរឿងរ៉ាវត្រូវស្បថ ឬ ប្រាថ្នាអ្វី អញ្ជើញទៅបួងសួងក្នុងព្រះវិហារច្រើនតែបានសម្រេចដូចក្តីបំណង ។ ដូចនៅជំនាន់លោកឧកញ៉ាមហា សឺន គុយ នៅមុនពេល ដែលលោករៀបចំទ័ពទៅវាយទ័ពយួន អុងឡូវ អុងបូ នៅវត្តពោធិវង្ស កំពង់ដូង ឬ វត្តផ្ទោដូង នោះ លោកបានចូលទៅថ្វាយបង្គំព្រះពុទ្ធរូបក្នុងព្រះវិហារ រួចសូមឲ្យព្រះអង្គជួយប្រោះព្រំរិទ្ធិចេស្តាដើម្បីទទួលបានជ័យជំនះលើទ័ពយួន ហើយក៏បានសម្រេចដូចសេចក្តីប្រាថ្នា ។ សូមស្លេះពីរឿងព្រះពុទ្ធរូបដ៏សក្តិសិទ្ធិមួយអង្គនៃវត្តចេតិយនេះសិន ។ ជាបន្តទៅទៀតនេះ សូមនិយាយពីរឿងស្តូបចេតិយ ដែលកសាងឡើងដើម្បីឧទ្ទិសចំពោះព្រះពុទ្ធសាសនា និងព្រហ្មញ្ញសាសនា ។ ចេតិយ មានទំហំផ្ទៃ ជាង ១០០០ ម៉ែត្រក្រឡា និងមានកម្ពស់ ៦០ ម៉ែត្រ ហើយមានដាំត្បូងកែវមួយធំនៅពីលើកំពូល ហើយនៅពេលយប់មានពន្លឺរស្មីចិញ្ចែងចិញ្ចាចខ្លាំងណាស់ អាចមើលឃើញពីគ្រប់ទិសទី បើយើងចេញមកពីទីរួមខេត្ត ឬ សំឡឹងមើលពីខេត្តព្រះត្រពាំងមក យើងតែងមើលឃើញពន្លឺត្បូងកែវយ៉ាងច្បាស់នៅលើកំពូលចេតិយ ភ្លឺស្វាចដូចពន្លឺត្បូងពេជ្រអញ្ចឹងដែរ ។



វត្តចេតិយ ឬ វត្តចូឡាមណីចេតិយ ខេត្តព្រះត្រពាំង ដែលកសាងឡើងក្នុង ព.ស. ២០៣១ ត្រូវនឹង គ.ស. ១៤៨៨

តែជាអកុសលនៅក្នុងឆ្នាំ ១៨៦៣-១៩៥៣ សន្ធិសញ្ញាបារាំងបានដាក់អាណានិគមលើប្រទេសខ្មែរ ហើយបារាំងបានយកកម្ពុជាក្រោមធ្វើអាណានិគម នៅពេលនោះបារាំងឃើញត្បូងកែវ ដ៏ល្អនៅលើកំពូលស្តូបចេតិយភ្លឺទាំងយប់ទាំងថ្ងៃយ៉ាងនេះ ពួកបារាំងក៏បានបាញ់ទំលាក់កំពូលចេតិយឲ្យធ្លាក់ចុះមកក្នុងបំណងនឹងយកត្បូងកែវនោះ ប៉ុន្តែបារាំងមិនអាចយកត្បូងកែវទិព្វនោះបានទេ ។ ត្បូងកែវដែលធ្លាក់ចុះនោះ ក៏បានរំកិលខ្លួនចុះទៅក្នុងស្រះទឹកមួយនៅក្បែរនោះបាត់ទៅ ពួកបារាំងក៏រុករកនៅសព្វទីកន្លែង តែរកពុំឃើញបាត់រហូតមកទល់សព្វថ្ងៃនេះ ។ ហើយកន្លែងស្រះដែលត្បូងកែវបាក់ធ្លាក់ចុះនោះ តាំងពីព្រះតេជគុណព្រះសង្ឃមុន ៗ ក៏ដូចជាបច្ចុប្បន្នព្រះអង្គតែងតែផ្តាំមិនឲ្យព្រះសង្ឃ ឬ នរណាម្នាក់ទៅជីកគាស់ កកាយ ឬចាក់សម្រាម ឬ ធ្វើអ្វីពុំសមរម្យនៅទីកន្លែងនោះបានឡើយ ៕

*អត្ថបទដកស្រង់ពីព្រឹត្តិបត្រសំឡេងនិស្សិត របស់សម្ព័ន្ធសមណនិស្សិត និស្សិតខ្មែរកម្ពុជាក្រោម ច្បាប់លេខ ០២ ឆ្នាំទី ០២ ឆ្នាំ ២០០៥*

# កុំស្លាប់ព្រោះតែស្ករយួន

មែន ! គួរយើងមើលសត្វស្រមោច ពួកគេស្លាប់ដោយសារការស្រេកឃ្លានទឹកស្ករ ដោយខ្វះការពិចារណា។

ចំពោះខ្មែរក្រោមយើងវិញ តើយួនរិះរកមធ្យោបាយយ៉ាងណាខ្លះ ដើម្បីសម្លាប់ខ្មែរ ហើយធ្វើឲ្យខ្មែរជឿបានថា យួនល្អនោះ ?

-យួនធ្វើឲ្យខ្មែរស្អប់ភាសាជាតិរបស់ខ្លួន ហើយចូលចិត្តនិយាយតែភាសាយួន ទោះបីខ្មែរជាមួយនឹងខ្មែរគ្នាឯងក្តី ក៏គេនិយាយភាសាយួនដែរ ព្រោះគេគិតថា ខ្លួនគេនិយាយភាសាយួនគ្រាន់បើជាងខ្មែរដទៃ ដែលនិយាយភាសាខ្មែរ ។ នេះពិតជាគំនិតរំលាយភាសាជាតិរបស់ខ្លួនដោយមិនដឹងខ្លួនមែន ។

-យួនធ្វើឲ្យខ្មែរ និងព្រះចៅអធិការវត្តមួយចំនួនឆ្កួតវង្វេងនឹងបុណ្យសក្តិ ។

-យួនតាមដាន និងស្រាវជ្រាវរកឈ្មោះខ្មែរស្នេហាជាតិ និងសម្លាប់បំបិទមុខ ចំពោះអ្នកប្រាជ្ញខ្មែរណាដែលមិនគោរពច្បាប់ផ្តាច់ការរបស់យួន ។

-យួនសាងសង់សាលាបាលី និងសាលារៀនឲ្យកូនខ្មែរ និងព្រះសង្ឃខ្មែររៀនក្តី សុទ្ធសឹងតែយួនបានលាបពណ៌បោកប្រាសភ្នែកខ្មែរអ្នកល្ងង់ខ្លៅទាំងអស់ (ចំពោះខ្មែរណាដែលថា យួនល្អនឹងខ្មែរ) ។

ចូរបងប្អូនខ្មែរ និងព្រះសង្ឃខ្មែរ ពិចារណាផងចុះ ទោះបីយួនសាងសង់សាលារៀនជាច្រើន ឲ្យព្រះសង្ឃខ្មែរ និងកូនខ្មែរបានរៀនសូត្រក្តី ក៏យួនមិនដែលឲ្យយើងជាខ្មែរបានរៀនសូត្រអំពីប្រវត្តិទឹកដីរបស់ខ្លួននោះទេ បើឲ្យរៀនវិញ គឺរៀនតាមរបៀបរបបយួនទាំងអស់ ។ យួនមិនដែលសារភាពថា ជាតិយួនរបស់ខ្លួនយកទឹកដីរបស់ខ្មែរនោះទេ ។

ខាងផ្នែកសាសនាវិញ យួនបានទិញទឹកចិត្ត និងលើកបន្តុបព្រះចៅអធិការមួយចំនួន ឲ្យមានឋានៈជាគណៈសង្ឃខេត្ត គណៈសង្ឃស្រុក ដើម្បីបម្រើផលប្រយោជន៍ឲ្យពួកគេប៉ុណ្ណោះ ។ ព្រះសង្ឃទាំងនោះ ត្រូវបានយួននិមន្តទៅប្រជុំកុហក់បោកប្រាសព្រះសង្ឃខ្មែរគ្នាឯងនៅហាណូយ ឬ ព្រៃនគរតាមរបៀបយួនលាបពណ៌ឲ្យទាំងអស់ ។

ចំពោះរឿងជាតិលិចលង់ផុងចុះដល់កម្រិតណា ក៏ដោយ ក៏ព្រះសង្ឃទាំងនោះ មិនខ្វីរវីរវល់ឡើយ ។ មានវត្តមួយចំនួន ប្រជារាស្ត្រខ្មែរបានអស់ជំនឿទៅលើព្រះចៅអធិការទៀតផង ដោយគេបានឃើញព្រះចៅអធិការទាំងនោះ ស៊ីប្រាក់ខែរបស់យួន ធ្វើការបម្រើនយោបាយបោកប្រាសឲ្យយួន ។

នៅមានព្រះសង្ឃ និងបងប្អូនខ្មែរមួយចំនួន បានពោលថា ខ្មែរក្រោមយើងធ្វើការតស៊ូនឹងយួន ធ្វើម្តេចនឹងឈ្នះយួន ព្រោះគេមានប្រជាពលរដ្ឋក៏ច្រើន អ្នកប្រាជ្ញរបស់គេក៏សឹងមានច្រើន ហើយគេមិនទាន់បានបូកបញ្ចូលនឹងក្រុមយួនធីវគីផង ។

បងប្អូនរួមឈាមខ្មែរ និងព្រះសង្ឃខ្មែរ មេត្តាកុំមានគំនិតរវើរវាយរបៀបខាងលើនោះទៀត ព្រោះវាខុសនឹងច្បាប់អន្តរជាតិឆ្ងាយគីឡូដីច្រើនណាស់ ។ បច្ចុប្បន្ននេះ អន្តរជាតិកំពុងមានច្បាប់លុបបំបាត់ទាំងរបបអាណានិគមចាស់ និងអាណានិគមថ្មីចោល ។ ប្រៀបបាននឹងអាណានិគមយួន ដែលជាអាណានិគមថ្មី បន្តវេនពីអាណានិគមចាស់ គឺបារាំងសែស ដូច្នោះដែរ គឺត្រូវលុបបំបាត់ចោលទាំងស្រុង នូវរបបអាណានិគមលើទឹកដីកម្ពុជាក្រោម ។

សូមបញ្ជាក់បន្ថែម ជូនបងប្អូនខ្មែរក្រោមយើង ឲ្យបានជ្រាបច្បាស់ថា តើហេតុអ្វីបានជាយួនមានចិត្តល្អនឹងបងប្អូនរួមឈាមខ្មែរក្រោមយើងម្ល៉េះ ? ត្រង់កន្លែងនេះ ល្មមបងប្អូនយើងយល់ ហើយយកមកពិចារណាផងមើល បើគ្មានអង្គការនយោបាយរបស់សហព័ន្ធខ្មែរកម្ពុជាក្រោម ធ្វើសេចក្តីរាយការណ៍អំពីបញ្ហាយួនរំលោភសិទ្ធិ ឬ កិច្ចផ្សេង ៗ ដែលយួនធ្វើមកលើខ្មែរក្រោមយើង ជូនអង្គការសហប្រជាជាតិទេនោះ ធ្វើម្តេចនឹងយួនមានចិត្តល្អនឹងខ្មែរក្រោមទៅសង់ផ្ទះ សង់សាលាបាលី ឬ សាលាឲ្យខ្មែរក្រោមយើងនោះ ។ បងប្អូនរួមឈាមខ្មែរក្រោមយើងជ្រាបស្រាប់ហើយ យួនគេធ្វើនយោបាយរំលាយ និងសម្លាប់ខ្មែរយើង ពីជំនាន់មួយទៅជំនាន់មួយ មានទាំងធម៌ក្តៅ និងតាមបែបត្រជាក់ ហើយផ្អែមល្ហែមទន់ភ្លន់ទៀតផង ។

ចូរខ្មែរក្រោមយើងគ្រប់ ៗ គ្នា កុំបីធ្វេសប្រហែសចាញ់កលល្បិចយួនឲ្យសោះ ទោះបីយួនធ្វើល្អយ៉ាងណា ក៏ដោយ កុំបីភ្លេចខ្លួនខ្វះការពិចារណា ធ្លាក់ចុះជឿងាប់ ព្រោះសម្តីផ្អែមរបស់យួន ៕

**សភាព្រឹទ្ធាចារ្យសហព័ន្ធខ្មែរកម្ពុជាក្រោម**

# យួនត្រូវតែបញ្ឈប់ជាបន្ទាន់ នូវនយោបាយឧបនិយកម្មភូមិសាស្ត្រ ប្រវត្តិសាស្ត្រកម្ពុជាក្រោម

សន្តតិវង្ស ង្វៀង នៃរាជវង្សអណ្ណាមរបស់យួន ដែលយួនសព្វថ្ងៃនេះបានអួតអាងថា ជាអ្នកកាប់ឆ្ការបើកទូលាយចុះមកភាគខាងត្បូងនោះ មិនមែនជាចលនាទេសន្តរប្រវេសន៍មកកាន់ទឹកដីដែលគ្មានម្ចាស់នោះទេ គឺជាការសម្រុកចុះដណ្តើមកាន់កាប់ទឹកដីដែលជាកម្មសិទ្ធិរបស់នគរខ្មែរនៅភាគខាងត្បូង ។ ពាក្យដែលយួនអួតថា កាប់ឆ្ការបើកទូលាយចុះមកភាគខាងត្បូងនោះ គឺជាការចុះមកកាប់សម្លាប់ជនជាតិដើមខ្មែរកម្ពុជាក្រោមដើម្បីប្លន់ដី ហើយក៏មិនមែនដើម្បីធ្វើអាណានិគមដែរ គឺដើម្បីប្រល័យពូជសាសន៍ជនជាតិដើមខ្មែរកម្ពុជាក្រោមម្ចាស់ស្រុកឲ្យផុតពូជ ។

ប៉ុន្តែជាភ័ព្វសំណាងអាក្រក់របស់យួន ដែលមិនអាចសម្លាប់ផ្តាច់ពូជខ្មែរកម្ពុជាក្រោមបាន ព្រោះមានការតស៊ូទប់ទល់ដ៏ស្វិតស្វាញនៃជនជាតិដើមខ្មែរកម្ពុជាក្រោមគ្រប់ជំនាន់ ទើបយួនប្រើនយោបាយយួនូបនិយកម្ម និងសន្តិភាវូបនិយកម្មជាដំណាក់ ៗ ហើយពួកយួនបានព្យាយាមបញ្ចៀសឲ្យផុតអំពីនយោបាយ ឬ ពាក្យថាធ្វើអាណានិគមលើជនជាតិដើមខ្មែរកម្ពុជាក្រោម ដូចជា ៖ កាលពីថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ១៩៦៩ រដ្ឋសភាយួនចំនួន ១២០ រូប អនុម័តិយល់ព្រម និង ៩០ រូបជំទាស់លើសេចក្តីព្រាងច្បាប់របស់រដ្ឋាភិបាលង្វៀង យ៉ាំង ធីវ ដាក់ខ្មែរកម្ពុជាក្រោមចំនួន ៦០០.០០០ នាក់ (ជាងកន្លះលាននាក់) "ជាយួនមានកំណើតខ្មែរ" (Nguoi Viet Goc Mien) ហើយពួកយួនកុម្មុយនិស្តសព្វថ្ងៃនេះ ហៅខ្មែរកម្ពុជាក្រោមចំនួនរាប់លាននាក់ ថា "ខ្មែរណាមបូ" នៅប្រទេសវៀតណាម ។ ការណ៍នេះអាចនិយាយបានថា ដោយអាស្រ័យអង្គការសហប្រជាជាតិបានធ្វើសច្ចានុម័តិលើច្បាប់លេខ ៥៥/១៤៦ ស្តីពីការបញ្ចប់អាណានិគមលើជនជាតិដើមកំណើតនៃប្រទេសនីមួយ ៗ ក្នុងសកលលោក កាលពីថ្ងៃទី ០៨ ធ្នូ គ.ស. ២០០០ នោះ ទើបយួនកុម្មុយនិស្តគិតឃើញថា បើខ្លួនធ្វើអាណានិគមមកលើខ្មែរកម្ពុជាក្រោម ត្រូវតែអនុវត្តតាមច្បាប់លេខ ៥៥/១៤៦ នេះ គឺ ត្រូវដកអាណានិគមចេញពីមាតុភូមិនៃប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោម ដែលមានទំហំ ៦៨.៦០០ គីឡូម៉ែត្រក្រឡា គឺស្ថិតនៅភូមិភាគខាងត្បូង នៃប្រទេសវៀតណាមសព្វថ្ងៃនេះ ។ ប៉ុន្តែយួនស្តាយចំណីឆ្ងាញ់ ដែលកំពុងទំពារក្នុងមាត់នេះហើយ ទើបខំបិទបាំងការពិត ព្រោះយួនខ្លាចអង្គការសហប្រជាជាតិខ្វេះចេញពីមាត់ ប្រគល់មកឲ្យខ្មែរកម្ពុជាក្រោមជាម្ចាស់ដើមវិញ ។

ទទ្បីករណ៍មួយទៀត ដែលឆ្លុះបញ្ចាំងឲ្យឃើញនូវទង្វើថោកទាប និងអាម៉ាស់បំផុតរបស់យួន ដែលខិតខំធ្វើនយោបាយយួនូបនិយកម្មភូមិសាស្ត្រ ប្រវត្តិសាស្ត្រខ្មែរកម្ពុជាក្រោមឲ្យទៅជាយួនដោយប្រើភាសាសងបំណុលនោះ បានបញ្ជាក់ឲ្យឃើញយ៉ាងច្បាស់ថែមទៀតថា ៖ "នេះបានចំជាចោរលួចគេ ហើយថាមិនមែនចោរទៀត" ភ័ស្តុតាងច្បាស់ក្រឡែត គឺភ្នៅនៅថ្នក់ទំពក់នៅដៃ គ្រាន់តែយកផ្លែភ្នៅទៅភ្ជាប់ជាមួយទងទៅក៏ដឹងថា ជាផ្លែភ្នៅរបស់អ្នកណាទៅហើយ ។

យ៉ាំងណាមិញ គ្រាន់តែខ្មែរកម្ពុជាក្រោមលើកយកភាសាសងបំណុល ដែលយួនប្រើសម្រាប់ឧបនិយកម្មភូមិសាស្ត្រ ប្រវត្តិ-សាស្ត្រកម្ពុជាក្រោមនោះ ក៏រកឃើញចោរប្លន់ដីនោះ ជាយួនទៅហើយ ចុះទម្រាំទទ្បីករណ៍នៅផ្សេង ៗ ទៀតជាច្រើននោះ តើយួនអាចគេចរួចពីការធ្វើអាណានិគមមកលើខ្មែរកម្ពុជាក្រោមបានដែរ ឬទេ ? តើអាចគេចឲ្យរួចពីសំណាញ់ច្បាប់អង្គការសហប្រជាជាតិ ស្តីពីការបញ្ចប់អាណានិគមលើជនជាតិដើម នៃប្រទេសណាមួយក្នុងសកលលោកបានដែរឬទេ ? យួនប្រាកដជាមិនអាចដោះសារយករួចខ្លួនបានទេ បើយួនមិនអាចគេចឲ្យផុតពីកំហុសដ៏ធំនេះ យួនត្រូវតែទទួលស្គាល់ថា ខ្លួនជាអ្នកធ្វើអាណានិគមមកលើជនជាតិដើមខ្មែរកម្ពុជាក្រោម ហើយត្រូវដកអាណានិគមចេញជាបន្ទាន់ ទុកលទ្ធភាពដល់ខ្មែរកម្ពុជាក្រោមសម្រេចវាសនាខ្លួនដោយខ្លួនឯង ក្នុងព្រំដែននៃបូរណភាពទឹកដីរបស់ខ្លួន ។

ជនជាតិដើមខ្មែរកម្ពុជាក្រោម មិនត្រូវការសំណងមាតុភូមិដែលពួកយួនសងត្រឹមតែភាសាបំណុលប៉ុណ្ណោះទេ គឺត្រូវការមាតុ-ភូមិដ៏ពិតប្រាកដ និងភាសាដើមទាំងស្រុង ដែលជារបស់ខ្មែរ ។

តើអ្វីដែលហៅថា ភាសាសងបំណុល ?

ភាសាសងបំណុល គឺភាសាដើមរបស់ជនជាតិដើម ឬពូជសាសន៍ណាមួយ បានប្រើ ឬ និយាយសម្គាល់វត្ថុ ឬ របស់អ្វី ៗ ផ្សេងៗ ដែលជនជាតិ ឬ ពូជសាសន៍ដទៃលួចពាក្យនោះយកទៅកាឡៃធ្វើជារបស់ខ្លួន ប៉ុន្តែមិនអាចលប់សំនៀងដើមទាំងស្រុងឡើយ មាននៅសំណល់ស័ព្ទដើម ដែលអាចស្តាប់ទៅនៅសម្គាល់បានប្រភព ឬ កំណើតដើមនៃពាក្យថា ជារបស់ជាតិណាមួយនោះ ។

ភាសាដើមរបស់ខ្មែរកម្ពុជាក្រោម បានហៅឈ្មោះខេត្តដែលយួនបានកាឡៃកើតទៅជាភាសាសងបំណុល ឧទាហរណ៍ដូចជា ៖ ខេត្តស្រុកទ្រាំង យួនហៅថា សុកត្រាំង, ខេត្តទឹកខ្មៅ យួនហៅថាកាម៉ៅ, ខេត្តមេស យួនហៅថាមីថ, ស្រុកបាយឆៅ យួនហៅថាបាយសៅ, ភូមិចុងផ្នោរ (ស្រុកកំពង់ស្ពាន) យួនហៅថាអឹបចុងណោ, ភ្នំនំអន្សម (ខេត្តមាត់ជ្រូក) យួនហៅថា នូយសាម, ភ្នំដាក់ព្រះបាទ (ខេត្តទឹកខ្មៅ) យួនហៅថា ហាងដាបាក ឬ ព្រែកហ្លួង (ខេត្តទឹកខ្មៅ) យួនហៅថា គិញលោង ជាដើម ។ល។

ពួកយួនប្រាកដជាមិនដឹងទេថា អ្វីដែលហៅថាភាសាសងបំណុលនោះ ប្រសិនបើស្ថានភាពនយោបាយក្នុងមាតុភូមិ និងក្នុងពិភពលោកដូចពីអតីតកាលនោះ ខ្មែរកម្ពុជាក្រោមប្រាកដជាមិនបង្ហើបចំណុចនេះទេ ប៉ុន្តែពេលនេះបើយួនបានដឹងវាហួសពេលទៅហើយ ព្រោះថាយួនមិនអាចឧបនិយកម្មភូមិសាស្ត្រ ប្រវត្តិសាស្ត្រកម្ពុជាក្រោមឲ្យផុតពីភាសាសងបំណុលបានឡើយ ៕

ព្រះត្រពាំង, ថ្ងៃទី ២៥ កញ្ញា ព.ស. ២៥៤៨, គ.ស. ២០០៥

ថាច់ ប៉ាំង




**បញ្ញាសជាតក**
**រឿងទី ១៤**

ជាស្នាដៃនិពន្ធរបស់លោក **ញ៉ុក ថែម**
បោះពុម្ពលើកទី ១ នៅភ្នំពេញ ឆ្នាំ ១៩៥៩

# រឿងមហាសុរសេន

កាលណោះ មានព្រះមហាក្សត្រមួយអង្គ ព្រះនាមព្រះបាទមហាសុរសេន សោយរាជ្យក្នុងព្រះនគរពារាណសី តែងទ្រង់ទូន្មានមហាជនរាល់ព្រឹកល្ងាចថា "អ្នកទាំងឡាយ កុំបីមានសេចក្ដីប្រមាទ ចូរនាំគ្នាធ្វើបុណ្យឲ្យទានរក្សាសីល" ។ ទ្រង់ឲ្យសាងសង់សាលាទាន ៦ ចំណាយព្រះរាជទ្រព្យមួយថ្ងៃមួយសែនកហាបណៈ ដាក់ទានដល់ស្មូមយាចករៀងរាល់ថ្ងៃ ។

ថ្ងៃមួយទ្រង់ព្រះចិន្ដាថា សព្វថ្ងៃនេះទ្រង់បានធ្វើពាហិរកទាន (ទានខាងក្រៅខ្លួន) សព្វគ្រប់ហើយ ប៉ុន្តែអជ្ឈត្តិកទាន (ទានខាងក្នុងខ្លួន) មិនទាន់បានបំពេញសោះ ។ ធម្មតា ព្រះពោធិសត្វទាំងឡាយ តែងធ្វើមហាបរិច្ចាគទាំង ៥ ប្រការ[១] ទើបបានត្រាស់ជាព្រះពុទ្ធ បើមានស្មូមណាមួយមកសូមភ្នែកក្ដី បេះដូងក្ដី សាច់ឈាមក្ដី អវយវៈណាមួយក្ដី ទ្រង់នឹងបរិច្ចាគជាទានដល់ស្មូមនោះ ៗ ក្នុងកាលឥឡូវនេះ ។

គ្រានោះ ព្រះឥន្ទ្រាធិរាជ ទ្រង់ជ្រាបទឹកព្រះទ័យនៃព្រះបាទមហាសុរសេនដូច្នោះហើយ ក៏ចុះពីទេវលោកមកកាន់ឋានមនុស្សលោក ។ ព្រះឥន្ទ្រទ្រង់និម្មិតអាត្មាជាមាណពឥតក្បាលដៃកាន់ឈើច្រត់ឈរបង្ហាញខ្លួននៅទីព្រះលាន នៃព្រះមហាក្សត្រ ។ ព្រះបាទមហាសុរសេន ទ្រង់គ្រឿងអលង្ការ មានអាមាត្រមុខមន្ត្រីហែហមអមព្រះអង្គ ស្ដេចឡើងគង់ព្រះទីនាំងគជេន្ទ្រឆ្ពោះទៅឯសាលាទាន ។ មាណពឥតក្បាល ក៏លើកដៃប្រណម្យបង្គំទូលថា "បពិតព្រះរាជសម្ភារ ទូលព្រះបង្គំជាមនុស្សឥតក្បាល សូមទ្រង់ព្រះរាជទានព្រះសិររបស់ព្រះអង្គឲ្យទូលព្រះបង្គំដោយក្ដីអនុគ្រោះដ៏ខ្ពង់ខ្ពស់របស់ព្រះអង្គ"[២] ។

អាមាត្យមុខមន្ត្រីនឹងមហាជនផង បានស្ដាប់សំដីនៃមាណពកំបុតក្បាលនោះ ក៏មានក្ដីតក់ស្លុតរន្ធត់ក្នុងចិត្តមហិមា ។ ឯព្រះមហាក្សត្រទ្រង់មានព្រះឱង្ការថា "ម្នាលមាណព អ្នកសូមរបស់អ្វីយើងនឹងឲ្យរបស់នោះ ឥតទើសទាល់ឡើយ យើងនឹងបំពេញបំណងរបស់យើងផង របស់អ្នកផង ថ្ងៃនេះយើងនឹងដាក់ទានក្បាលយើងឲ្យអ្នក យើងប្រាថ្នាសូមឲ្យបានត្រាស់ជាព្រះពុទ្ធមួយអង្គស្រោចស្រង់សត្វលោកទៅអនាគតកាល" ។ ទ្រង់បានប្រទានព្រះខ័នទៅអាមាត្យម្នាក់ ឲ្យកាត់ព្រះសិរសាព្រះអង្គ ។ អាមាត្យនោះឈរសម្រក់ទឹកភ្នែក មិនអាចប្រតិបត្តិតាមព្រះឱង្ការឡើយ ហើយទ្រង់ចាប់ព្រះខ័នកាត់ព្រះសុរងដាច់ចេញពីព្រះកាយ ព្រះរាជទានទៅមាណពឥតក្បាលនោះមួយរំពេច ។ កាលណោះស័ព្ទយោបំយំសោក មានព្រះអគ្គមហេសីនឹងស្រីស្នំជាដើម លាន់ឮកងរំពងទូទៅ ដោយក្ដីសោកស្ដាយអាឡោះអាល័យព្រះមហាក្សត្រ ។ សេចក្ដីអស្ចារ្យផ្សេង ៗ ក៏កើតមានប្រាកដជាក់ស្ដែង មហាប្រឹថពីក៏កម្រើកញាប់ញ័រសូរស័ព្ទផ្គរក៏លាន់ឮគគ្រឹកគគ្រេង ភ្លៀងផ្កាប្រាំពណ៌ក៏បង្អុរធ្លាក់ចុះពីអាកាសដោយតេជៈទានបរមត្ថបារមីនៃព្រះមហាក្សត្រ ។

ខណៈនោះ ព្រះឥន្ទ្រាធិរាជជាម្ចាស់នៃត្រៃត្រិង្សទេវលោក ទ្រង់គ្រឿងអលង្ការទិព្វដ៏រុងរឿង ទ្រង់ស្ថិតឰដ៏អាកាស ទ្រង់បង្ហាញព្រះអង្គ ឲ្យមហាជនប្រុសស្រីបានឃើញជាក់ស្ដែងរាល់គ្នា ហើយទ្រង់មានទេវឱង្ការនឹងព្រះនាងទេវីថា "ម្នាលព្រះនាង កុំទ្រង់កន្សែងសោយសោកពេកឡើយ យើងនឹងប្រទានជីវិតដល់ព្រះរាជស្វាមីនៃព្រះនាង ក្នុងកាលឥឡូវនេះឯង" ។ដោយ

---

*១-បញ្ចមហាបរិច្ចាគ ប្រែថា ៖ បរិច្ចាគធំ ៥ ប្រការ គឺបរិច្ចាគសរីរាវយវៈ ១ បរិច្ចាគទ្រព្យ ១ បរិច្ចាគជីវិត ១ បរិច្ចាគកូន ១ បរិច្ចាគប្រពន្ធ ១ ។*

*២-មាណពឥតក្បាលបានមាត់ពីណានិយាយ ? តាមធម្មតាមនុស្សសត្វក្ដី តែឥតក្បាលហើយមិនដែលមានជីវិតរស់នៅកើតទេ តែក្នុងរឿងនេះ អ្នកនិពន្ធបង្កើតបរិយាកាសយ៉ាងចម្លែកបែបនេះ មិនសូវសមហេតុសមផលទេ ទោះជាទុកដាក់ជារឿងអច្ឆរិយគតិក៏ ដោយ ។*

តេជៈកុសលសម្ភារនៃព្រះមហាក្សត្រ និងទេវានុភាព ព្រះសិរសាក៏កើតឡើងវិញដូចដើមក្នុងខណៈនោះឯង ។ មនុស្សម្នាមហាជនក៏ថ្វាយស័ព្ទសាធុការពរលាន់ឮកងរំពងទូទៅ ទាំងព្រះរាជវង្សានុ-វង្សបានឃើញការណ៍អស្ចារ្យដូច្នោះ ក៏ព្រឺព្រួចលោមាមានក្តីត្រេកអរសោមនស្សរីកមហិមា ។ ព្រះបាទមហាសុរសេនក្រោយដែលទ្រង់មានព្រះជន្មឡើងវិញហើយ ទ្រង់តែងបំពេញកុសលមានទានសីលជាដើមជានិច្ច រៀងរហូតដល់សោយទិវង្គត ស្តេចបានទៅកើតក្នុងតុសិតពិភព សេពសោយសម្បត្តិទិព្វជានិរន្តរ៍ ៕

# សេចក្តីថ្លែងអំណរគុណ

## របស់ប្រធានសតាព្រឹទ្ធាចារ្យសហព័ន្ធខ្មែរកម្ពុជាក្រោម

ប្រធានសតាព្រឹទ្ធាចារ្យ នៃសហព័ន្ធខ្មែរកម្ពុជាក្រោម សូមថ្លែងអំណរគុណ ៖

-ប្រធានតូមិតាគទី ១ ៖ លោក ត្រឹង ជី និង សមាជិក-សមាជិកាគ្រប់ជាន់ថ្នាក់ ។

-ប្រធានតូមិតាគទី ២ ៖ លោក ហាង រឿង ព្រមទាំងសមាជិក-សមាជិកាគ្រប់ជាន់ថ្នាក់ ។

-ប្រធានតូមិតាគទី ៣ ៖ លោក ថាច់ តង ព្រមទាំងសមាជិក-សមាជិកាគ្រប់ជាន់ថ្នាក់ ។

-ប្រធានតូមិតាគទី ៤ ៖ លោក ថាច់ ដារ៉ា ព្រមទាំងសមាជិក-សមាជិកាគ្រប់ជាន់ថ្នាក់ ។

ដែលបានយកចិត្តទុកដាក់ចំពោះជាតិ បានឧបត្ថម្ភថវិកា ជូនដល់ការិយាល័យសតាព្រឹទ្ធាចារ្យបានប្រាំពីររយដុល្លារសហរដ្ឋអាមេរិក ។ ដើម្បីការិយាល័យ យកទៅថ្វាយប្រគេនដល់ព្រះសង្ឃវត្តសាមគ្គីរង្សី ហៅបឹងក្រពើ នៅព្រះរាជាណាចក្រកម្ពុជា ដែលបានរងគ្រោះ ដោយមហន្តរាយអគ្គីភ័យឆាបឆេះនៅពេលថ្មី ៗ នេះ ។

តាងនាមខ្ញុំ តំណាងឲ្យសហព័ន្ធខ្មែរកម្ពុជា-ក្រោម និងតំណាងឲ្យលោកអធិបតី រួមទាំងគ្រប់ក្រសួងនៃស្ថាប័នសហព័ន្ធខ្មែរកម្ពុជាក្រោម ។

សូមថ្លែងអំណរគុណ និងជូនពរជ័យ ចូរមានដល់អស់លោកប្រធាន និងសមាជិក-សមាជិកា សូមអស់លោក ជួបតែសេចក្តីសុខចម្រើនគ្រប់បែបយ៉ាងកុំបីអាក់ខានឡើយ ។

ម៉្យាង សូមអស់លោកសម្រេចបានកិច្ចការជាតិខ្មែររបស់យើងនៅគ្រប់ដំណើរការ ៕

# ផលិតកម្មខ្មែរក្រោម




**Vol. 05 មាន ១២ បទ**

ដែលជាចម្រៀងស្នេហាជាតិ ប្រកបដោយមនោសញ្ចេតនានឹកស្រណោះភូមិស្រុក រំឭកអំពីប្រវត្តិសោកនាដកម្ម និងទទួលអំណរនូវសមិទ្ធិផលថ្មី ៗ នៃកម្លាំងសាមគ្គី ដែលខ្មែរក្រោមទើបតែទទួលបាន ក្រោមមាគ៌ាដឹកនាំរបស់សហព័ន្ធខ្មែរកម្ពុជាក្រោម ។ សូមអញ្ជើញទាក់ទង ៖


**ចាងហ្វាងផលិតកម្ម**

**សឺន ខាន់**

P.O. Box 8362, Tacoma, WA 98418
Tel: (253) 988-5239


**រៀបរៀងដោយ អ្នកស្រី កៀង សាខន**

**ពិនិត្យដោយ លោក ថាច់ ង៉ុក ថាច់**

## កម្លាំងសាមគ្គី

*ដកស្រង់ចេញពីផលិតកម្មខ្មែរក្រោម Vol. 05*
*និពន្ធដោយ លោក* **ថាច់ ង៉ុក ថាច់**
*ច្រៀងជាពួក*

ពោល ៖ ជយោ...! សហព័ន្ធខ្មែរកម្ពុជាក្រោមពិភព-លោក !

៖ ជយោ...! កម្លាំងសាមគ្គី !

៖ ជយោ...! ខ្មែរក្រោម...!

ច្រៀង ១-សាមគ្គី...ៗ...ៗ...ៗ...

សហព័ន្ធខ្មែរកម្ពុជាក្រោមមានជ័យ សាមគ្គីពួតដៃទាមទារសិទ្ធិជូនជាតិខេមរា ស្ម័គ្របម្រើជាតិស្មោះញាតិហើយនិងសាសនា គ្រប់គ្នាប្ដេជ្ញាការពារបូរណភាពទឹកដី ។

២-ប្ដឹងគ្រប់ទិសទីយកច្បាប់តតាំងសត្រូវ កាប់ព្រៃបើកផ្លូវឆ្ពោះទៅកាន់មហាវិថី ក្រោមលើកណ្ដាលរួចគ្នារំដោះទឹកដី សាងជីវិតថ្មីលើដីដំណែលកេរ្ដិ៍ដូនតា

សាមគ្គី...ៗ...ៗ...ៗ ។

( ភ្លេង.... )

R-សាមគ្គី...ៗ...ៗ...ៗ...

ប្ដឹងគ្រប់ទិសទីយកច្បាប់តតាំងសត្រូវ កាប់ព្រៃបើកផ្លូវឆ្ពោះទៅកាន់មហាវិថី ក្រោមលើកណ្ដាលរួចគ្នារំដោះទឹកដី សាងជីវិតថ្មីលើដីដំណែលកេរ្ដិ៍ដូនតា ។

៣-ថ្ងៃរះព្រាងៗឯឡើងក៏ជិតរាំងដែរ បងប្អូនកូនខ្មែរទាំងអ្នកស្រែនិងអ្នកចម្ការ និស្សិតបញ្ញវន្តរួសរាន់កុំនៅអរា រួមកម្លាំងគ្នា ប្ដឹងទាមទារសិទ្ធិសេរីភាព

សាមគ្គី...ៗ...ៗ...ៗ ៕